# អាដានាដិយសូត្រ (អាដានាដិយបរិត្ត)

## (បិដក អដ្ឋកថា ដីកា)



ដកស្រង់រៀបរៀងដោយភិក្ខុ ទួន សារ៉េត ព.ស២៥៦៦, គ.ស២០២៣

# សេចក្ដីផ្ដើម

សៀវភៅនេះ ខ្ញុំព្រះករុណា អាត្មាភាព ភិក្ខុ សារត្ថធម្មោ នួន សារ៉េត បាន រៀបរៀងឡើង ដើម្បីជាប្រយោជន៍ដល់ពុទ្ធបរិស័ទទូទៅ បានការសិក្សាស្រាវជ្រាវ និង បដិបត្តិក្នុងព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ ដើម្បីជាប្រយោជន៍ ដល់សង្គមជាតិ សាសនា របស់ខ្មែរយើង នឹងជួយជាចំណេះដឹង ដល់កុលបុត្រ កុលធីតា ប្អូនៗ បងៗ ជា និស្សិត ក្នុងសៀវភៅនេះផងដែរ ។

ពិតណាស់ សង្គមមួយ ដែលមានមនុស្សចេះដឹងច្រើន យល់ដឹងច្រើន នឹង ឈានទៅរកការអភិវឌ្ឍបានរីកចម្រើន ភាពសម្បូរសប្បាយ លូតលាស់ ជឿនលឿន ប្រកបដោយសុខចម្រើន ក្នុងសង្គមនោះពុំខាន ។ ហេតុនេះហើយ ខ្ញុំព្រះករុណា អាត្មាភាព នឹងសង្ឃឹមថា សៀវភៅនេះ នឹងបានជាយោជន៍ដល់ជនច្រើន ។

សេចក្ដីរៀបរាប់មកខាងលើនេះ សូមជូនពរ ឲ្យពុទ្ធបរិស័ទទាំងអស់ និង ប្អូនៗ បងៗ សិក្សា បដិបត្តិ ឲ្យបានជាប្រយោជន៍ ជាចំណេះដឹង ជាមេរៀន ជាមេគំនិត សម្រាប់ដំណើរជីវិតនេះ ប្រកបតែសេចក្ដីសុខ សេចក្ដីចម្រើន និង រួបចាកទុក្ខទាំងពួង កុំបីអាក់ខានឡើយ ។

សូមថ្វាយព្រះរាជកុសលនេះ ដល់ព្រះមហាក្សត្រាក្សត្រីខ្មែរគ្រប់ជំនាន់ និងថ្វាយ ព្រះរាជកុសលដល់ព្រះសង្ឃរាជទាំងទាំងពីរគណៈគ្រប់ជំនាន់ និងមន្ត្រីសង្ឃគ្រប់រូប ព្រមទាំងបុព្វបុរសវីរៈជនខ្មែរគ្រប់រូប ពុទ្ធបរិស័ទទាំងអស់ សូមអនុមោទនានូវធម្មទាន ដែលខ្ញុំព្រះករុណា អាត្មាភាព បានបំពេញនេះ ហើយសូមឲ្យតែបានសេចក្ដីសុខ សេចក្ដីចម្រើន និងរួបចាកទុក្ខទាំងពួងកុំបីអាក់ខានឡើយ ។

វត្តស្រះមុជ្ជលិន្ទ ថ្ងៃទី២១ ខែមេសាឆ្នាំ២០២៣

**សារត្ថធម្មោ នួន សារ៉េត**

## អាដានាដិយសូត្រ ទី៩ (អាដានាដិយបរិត្ត)

## (បិដកខ្មែរភាគ ១៩ ទំព័រ ៩៧)

[៧៨] ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់លើភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ លំដាប់នោះឯង ស្ដេចធំទាំង៤អង្គ តាំងការរក្សាទុកក្នុងទិសទាំង៤ តាំងកងពលទុក ក្នុងទិសទាំង៤ តាំងបុគ្គលជាអ្នកត្រួតត្រាទុក ក្នុងទិសទាំង៤ ដោយសេនាយក្ខ ដ៏ច្រើន ដោយសេនាគន្ធព្វដ៏ច្រើន ដោយសេនាកុម្ភណ្ឌដ៏ច្រើន ដោយសេនានាគដ៏ច្រើន កាលវេលារាត្រី (បឋមយាម) កន្លងទៅហើយ (ស្ដេចទាំងនោះ) មានពន្លឺដ៏រុងរឿង ញុំាងភ្នំគិជ្ឈកូដទាំងមូលឲ្យភ្លឺហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគក្នុងទីនោះ លុះចូលទៅដល់ហើយ ទើបក្រាបថ្វាយបង្គំព្រះមានព្រះភាគ ដោយគោរព ហើយអង្គុយក្នុងទីដ៏សមគួរ ។ ឯយក្ខទាំងឡាយនោះ ពួកខ្លះថ្វាយបង្គំព្រះមានព្រះភាគ ដោយគោរព ហើយអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះ គ្រាន់តែពោលពាក្យរាក់ទាក់សំណេះសំណាល ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ពួកខ្លះ គ្រាន់តែអង្គុយប្រណម្យអញ្ជលី ចំពោះព្រះមានព្រះភាគ ក្នុងទីដ៏សមគួរ ពួកខ្លះ គ្រាន់តែប្រកាសនាម និងគោត្រ អង្គុយក្នុងទីសមគួរ ពួកខ្លះ គ្រាន់តែអង្គុយស្ងៀម ក្នុងទីដ៏សមគួរ ។

[៧៩] ស្ដេចជាធំឈ្មោះវេស្សវណ្ណ គង់នៅក្នុងទីដ៏សមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ពួកយក្ខជាន់ខ្ពស់ មិនជ្រះថ្លាចំពោះព្រះមានព្រះភាគក៏មាន ពួកយក្ខជាន់ខ្ពស់ ជ្រះថ្លាចំពោះព្រះមានព្រះភាគក៏មាន បពិត្រព្រះអង្គដ៏ចំរើន បពិត្រព្រះអង្គដ៏ចំរើន ពួកយក្ខជាន់កណ្ដាល មិនជ្រះថ្លាចំពោះព្រះមានព្រះភាគក៏មាន ពួកយក្ខជាន់កណ្ដាល ជ្រះថ្លាចំពោះព្រះមានព្រះភាគក៏មាន បពិត្រព្រះអង្គដ៏ចំរើន ពួកយក្ខជាន់ទាប មិនជ្រះថ្លាចំពោះព្រះមានព្រះភាគក៏មាន បពិត្រព្រះ

អង្គដ៏ចំរើន ពួកយក្ខជាន់ទាប ជ្រះថ្លាចំពោះព្រះមានព្រះភាគក៏មាន ។ បពិត្រព្រះអង្គដ៏ចំរើន ឯយក្ខដែលមិនជ្រះថ្លា ចំពោះព្រះមានព្រះភាគច្រើនណាស់ ការនោះព្រោះហេតុអ្វី បពិត្រព្រះអង្គដ៏ចំរើន ព្រោះថា ព្រះមានព្រះភាគទ្រង់សំដែងធម៌ ដើម្បីឲ្យវៀរចាកបាណាតិបាត ទ្រង់សំដែងធម៌ ដើម្បីឲ្យវៀរចាកអទិន្នាទាន ទ្រង់សំដែងធម៌ ដើម្បីឲ្យវៀរចាកកាមេសុមិច្ឆាចារ ទ្រង់សំដែងធម៌ ដើម្បីឲ្យវៀរចាកមុសាវាទ ទ្រង់សំដែងធម៌ ដើម្បីឲ្យវៀរចាកទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាហេតុជាទីតាំងនៃសេចក្តីប្រមាទ ។ បពិត្រព្រះអង្គដ៏ចំរើន ចំណែកខាងយក្ខទាំងឡាយ ច្រើនតែមិនវៀរចាកបាណាតិបាតសោះ មិនវៀរចាកអទិន្នាទានសោះ មិនវៀរចាកកាមេសុមិច្ឆាចារសោះ មិនវៀរចាកមុសាវាទសោះ មិនវៀរចាកទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាហេតុជាទីតាំងនៃសេចក្តីប្រមាទសោះ បានជាពួកយក្ខទាំងនោះ មិនគាប់ចិត្ត មិនពេញចិត្តនឹងការវៀរនោះ ។ បពិត្រព្រះអង្គដ៏ចំរើន ពួកសាវ័ករបស់ព្រះមានព្រះភាគ អាស្រ័យនៅសេនាសនៈស្ងាត់ ដែលតាំងនៅក្នុងព្រៃ មានសូរសព្ទតិចតួចរំពងតិច ប្រាសចាកសំដីរបស់មនុស្សអ្នកដើរទៅមក សមគួរដល់ការកំបាំងអំពីពួកមនុស្ស ជាទីគួរដល់ការលាក់ខ្លួន ពួកអត្តាបាន ពួកយក្ខជាន់ខ្ពស់ តែងនៅជានិច្ចក្នុងព្រៃនោះ (គេ) មិនជ្រះថ្លាក្នុងសាសនា របស់ព្រះមានព្រះភាគក៏មាន បពិត្រព្រះអង្គដ៏ចំរើន ព្រោះហេតុនោះ សូមព្រះមានព្រះភាគ ប្រៀនប្រដៅនូវព្រះបរិត្តសម្រាប់រក្សាក្នុងនគរឈ្មោះ អាដានាដា ដល់ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ដើម្បីឲ្យយក្ខទាំងនោះជ្រះថ្លា ដើម្បីការគ្រប់គ្រងរក្សា ដើម្បីមិនបៀតបៀនគ្នា ដើម្បីនៅសប្បាយ ។ ព្រះមានព្រះភាគទ្រង់ទទួលនិមន្ត ដោយតុណ្ហីភាព ។ លំដាប់នោះ ស្តេចជាធំ ឈ្មោះវេស្សវ័ណ ជ្រាបនូវការទទួលនិមន្តព្រះមានព្រះភាគ ហើយទើបសំដែងនូវព្រះបរិត្តសម្រាប់រក្សា ដែលជាប់ទាក់ទង ក្នុងអាដានាដានគរនេះ ក្នុងវេលានោះ ។

(៨០) "វិបស្សិស្ស ច នមត្ថុ, ចក្ខុមន្តស្ស សិរីមតោ ។

សិខិស្សបិ ច នមត្ថុ, សព្វភូតានុកម្បិនោ។

“វេស្សភុស្ស ច នមត្ថុ, ន្ហាតកស្ស តបស្សិនោ;

នមត្ថុ កកុសន្ធស្ស, មារសេនាបមទ្ទិនោ។

“កោណាគមនស្ស នមត្ថុ, ព្រាហ្មណស្ស វុសីមតោ;

កស្សបស្ស ច នមត្ថុ, វិប្បមុត្តស្ស សព្វធិ។

“អង្គីរសស្ស នមត្ថុ, សក្យបុត្តស្ស សិរីមតោ;

យោ ឥមំ ធម្មំ ទេសេសិ, សព្ពទុក្ខាបនូទនំ។

“យេ ចាបិ និព្វុតា លោកេ, យថាភូតំ វិបស្សិសុំ;

តេ ជនា អបិសុណាថ, មហន្តា វីតសារទា។

“ហិតំ ទេវមនុស្សានំ, យំ នមស្សន្តិ គោតមំ;

វិជ្ជាចរណសម្បន្នំ, មហន្តំ វីតសារទំ។

(៨១) “យតោ ឧគ្គច្ឆតិ សូរិយោ, អាទិច្ចោ មណ្ឌលី មហា។

យស្ស ចុគ្គច្ឆមានស្ស, សំវរីបិ និរុជ្ឈតិ;

យស្ស ចុគ្គតេ សូរិយេ, ‘ទិវសោតិ បវុច្ចតិ។

“រហទោបិ តត្ថ គម្ភីរោ, សមុទ្ទោ សរិតោទកោ;

ឯវំ តំ តត្ថ ជានន្តិ, ‘សមុទ្ទោ សរិតោទកោ។

“ឥតោ ‘សា បុរិមា ទិសា, ឥតិ នំ អាចិក្ខតី ជនោ;

យំ ទិសំ អភិបាលេតិ, មហារាជា យសស្សិ សោ។

"គន្ធព្វានំ អធិបតិ , 'ធតរដ្ឋោ'តិ នាមសោ;
រមតី នច្ចគីតេហិ, គន្ធព្វេហិ បុរក្ខតោ។
"បុត្តាបិ តស្ស ពហវោ, ឯកនាមាតិ មេ សុតំ;
អសីតិ ទស ឯកោ ច, ឥន្ទនាមា មហព្វលា។
តេ ចាបិ ពុទ្ធំ ទិស្វាន, ពុទ្ធំ អាទិច្ចពន្ធុនំ;
ទូរតោវ នមស្សន្តិ, មហន្តំ វីតសារទំ។
"នមោ តេ បុរិសាជញ្ញ, នមោ តេ បុរិសុត្តម;
កុសលេន សមេក្ខសិ, អមនុស្សាបិ តំ វន្ទន្តិ;
សុតំ នេតំ អភិណ្ហសោ, តស្មា ឯវំ វទេមសេ។
"'ជិនំ វន្ទថ គោតមំ, ជិនំ វន្ទាម គោតមំ;
វិជ្ជាចរណសម្បន្នំ, ពុទ្ធំ វន្ទាម គោតមំ'។
(៨២) "យេន បេតា បវុច្ចន្តិ, បិសុណា បិដ្ឋិមំសិកា។
បាណាតិបាតិនោ លុទ្ទា , ចោរា នេកតិកា ជនា។
"ឥតោ 'សា ទក្ខិណា ទិសា, ឥតិ នំ អាចិក្ខតី ជនោ;
យំ ទិសំ អភិបាលេតិ, មហារាជា យសស្សិ សោ។
"កុម្ភណ្ឌានំ អធិបតិ, 'វិរូឡ្ហោ' ឥតិ នាមសោ;
រមតី នច្ចគីតេហិ, កុម្ភណ្ឌេហិ បុរក្ខតោ។
"បុត្តាបិ តស្ស ពហវោ, ឯកនាមាតិ មេ សុតំ;

អសីតិ ទស ឯកោ ច, ឥន្ទនាមា មហព្ពលា។
តេ ចាបិ ពុទ្ធំ ទិស្វាន, ពុទ្ធំ អាទិច្ចពន្ធុនំ;
ទូរតោវ នមស្សន្តិ, មហន្តំ វីតសារទំ។

"នមោ តេ បុរិសាជញ្ញ, នមោ តេ បុរិសុត្តម;
កុសលេន សមេក្ខសិ, អមនុស្សាបិ តំ វន្ទន្តិ;
សុតំ នេតំ អភិណ្ហសោ, តស្មា ឯវំ វទេមសេ។

"'ជិនំ វន្ទថ គោតមំ, ជិនំ វន្ទាម គោតមំ;
វិជ្ជាចរណសម្បន្នំ, ពុទ្ធំ វន្ទាម គោតមំ'។

(៨៣) "យត្ថ ចោគ្គច្ឆតិ សូរិយោ, អាទិច្ចោ មណ្ឌលី មហា។
យស្ស ចោគ្គច្ឆមានស្ស, ទិវសោបិ និរុជ្ឈតិ;
យស្ស ចោគ្គតេ សូរិយេ, 'សំវរី'តិ បវុច្ចតិ។

"រហទោបិ តត្ថ គម្ភីរោ, សមុទ្ទោ សរិតោទកោ;
ឯវំ តំ តត្ថ ជានន្តិ, 'សមុទ្ទោ សរិតោទកោ'។

"ឥតោ 'សា បច្ឆិមា ទិសា, ឥតិ នំ អាចិក្ខតី ជនោ;
យំ ទិសំ អភិបាលេតិ, មហារាជា យសស្សិ សោ។

"នាគានញ្ច អធិបតិ, 'វិរូបក្ខោ'តិ នាមសោ;
រមតី នច្ចគីតេហិ, នាគេហេវ បុរក្ខតោ។

"បុត្តាបិ តស្ស ពហវោ, ឯកនាមាតិ មេ សុតំ;

អសីតិ ទស ឯកោ ច, ឥន្ទនាមា មហព្វលា។

តេ ចាបិ ពុទ្ធំ ទិស្វាន, ពុទ្ធំ អាទិច្ចពន្ធុនំ;

ទូរតោវ នមស្សន្តិ, មហន្តំ វីតសារទំ។

“នមោ តេ បុរិសាជញ្ញ, នមោ តេ បុរិសុត្តម;

កុសលេន សមេក្ខសិ, អមនុស្សាបិ តំ វន្ទន្តិ;

សុតំ នេតំ អភិណ្ហសោ, តស្មា ឯវំ វទេមសេ។

‘‘‘ជិនំ វន្ទថ គោតមំ, ជិនំ វន្ទាម គោតមំ;

វិជ្ជាចរណសម្បន្នំ, ពុទ្ធំ វន្ទាម គោតមំ’’។

(៨៤) “យេន ឧត្តរកុរុវ្ហោ, មហានេរុ សុទស្សនោ។

មនុស្សា តត្ថ ជាយន្តិ, អមមា អបរិគ្គហា។

“ន តេ ពីជំ បវបន្តិ, នបិ នីយន្តិ នង្គលា;

អកដ្ឋបាកិមំ សាលឹ, បរិភុញ្ជន្តិ មានុសា។

“អកណំ អថុសំ សុទ្ធំ, សុគន្ធំ តណ្ឌុលប្ផលំ;

តុណ្ឌិកីរេ បចិត្វាន, តតោ ភុញ្ជន្តិ ភោជនំ។

“គាវឹ ឯកខុរំ កត្វា, អនុយន្តិ ទិសោទិសំ;

បសុំ ឯកខុរំ កត្វា, អនុយន្តិ ទិសោទិសំ។

“ឥត្ថិំ វា វាហនំ កត្វា, អនុយន្តិ ទិសោទិសំ;

បុរិសំ វាហនំ កត្វា, អនុយន្តិ ទិសោទិសំ។

"កុមារី វាហនំ កត្វា, អនុយន្តិ ទិសោទិសំ;
កុមារំ វាហនំ កត្វា, អនុយន្តិ ទិសោទិសំ។
"តេ យានេ អភិរុហិត្វា, សព្វា ទិសា អនុបរិយាយន្តិ ;
................................. បចារា តស្ស រាជិនោ។
"ហត្ថិយានំ អស្សយានំ, ទិព្វំ យានំ ឧបដ្ឋិតំ;
បាសាទា សិវិកា ចេវ, មហារាជស្ស យសស្សិនោ។
"តស្ស ច នគរា អហុ, អន្តលិក្ខេ សុមាបិតា;
អាដានាដា កុសិនាដា បរកុសិនាដា, នាដសុរិយា បរកុសិដនាដា។

"ឧត្តរេន កសិវន្តោ, ជនោឃមបរេន ច;
នវនវុតិយោ អម្ពរអម្ពរវតិយោ,
អាឡកមន្ទា នាម រាជធានី។
"កុវេរស្ស ខោ បន, មារិស,
មហារាជស្ស វិសាណា នាម រាជធានី;
តស្មា កុវេរោ មហារាជា,
'វេស្សវណោ'តិ បវុច្ចតិ។

"បច្ចេសន្តោ បកាសេន្តិ, តតោលា តត្តលា តតោតលា;
ឱជសិ តេជសិ តតោជសី, សូរោ រាជា អរិដ្ឋោ នេមិ។
"រហទោបិ តត្ថ ធរណី នាម, យតោ មេឃា បវស្សន្តិ;

វេស្សា យតោ បតាយន្តិ, សភាបិ តត្ថ សាលវតី នាម។

"យត្ថ យក្ខា បយិរុបាសន្តិ,
តត្ថ និច្ចផលា រុក្ខា;
នានា ទិជគណា យុតា,
មយូរកោញ្ចាភិរុទា;
កោកិលាទីហិ វគ្គុហិ។

"ជីវញ្ជីវកសទ្ទេត្ថ, អថោ ឱដ្ឋវចិត្តកា;
កុក្កុដកា កុឡីរកា, វនេ បោក្ខរសាតកា។

"សុកសាឡិកសទ្ទេត្ថ, ទណ្ឌមាណវកានិ ច;
សោភតិ សព្វកាលំ សា, កុវេរនឡិនី សទា។

"ឥតោ 'សា ឧត្តរា ទិសា, ឥតិ នំ អាចិក្ខតី ជនោ;
យំ ទិសំ អភិបាលេតិ, មហារាជា យសស្សិ សោ។

"យក្ខានញ្ច អធិបតិ, 'កុវេរោ' ឥតិ នាមសោ;
រមតី នច្ចគីតេហិ, យក្ខេហេវ បុរក្ខតោ។

"បុត្តាបិ តស្ស ពហវោ, ឯកនាមាតិ មេ សុតំ;
អសីតិ ទស ឯកោ ច, ឥន្ទនាមា មហព្វលា។

"តេ ចាបិ ពុទ្ធំ ទិស្វាន, ពុទ្ធំ អាទិច្ចពន្ធុនំ;
ទូរតោវ នមស្សន្តិ, មហន្តំ វីតសារទំ។

"នមោ តេ បុរិសាជញ្ញ, នមោ តេ បុរិសុត្តម;
កុសលេន សមេក្ខសិ, អមនុស្សាបិ តំ វន្ទន្តិ;
សុតំ នេតំ អភិណ្ហសោ, តស្មា ឯវំ វទេមសេ។
"ជិនំ វន្ទថ គោតមំ, ជិនំ វន្ទាម គោតមំ;
វិជ្ជាចរណសម្បន្នំ, ពុទ្ធំ វន្ទាម គោតម"ន្តិ។

សេចក្តីប្រែ

[៨០] សូមនមស្ការ ចំពោះព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមវិបស្សី ព្រះអង្គមានចក្ខុ ព្រះអង្គមានសិរី សូមនមស្ការ ចំពោះព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមសិខី ព្រះអង្គមានសេចក្តីអនុគ្រោះ ដល់សត្វទាំងពួងជាប្រក្រតី។ សូមនមស្ការ ចំពោះព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមវេស្សភូ ព្រះអង្គជម្រះកិលេសចេញហើយ ព្រះអង្គមានតបធម៌ សូមនមស្ការ ចំពោះព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមកកុសន្ធ: ព្រះអង្គញាំញីនូវមារ ព្រមទាំងសេនានៃមារ។ សូមនមស្ការ ចំពោះព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមកោនាគមន: ព្រះអង្គមានបាបបន្សាត់បង់ហើយ មានព្រហ្មចរិយធម៌នៅរួចហើយ  សូមនមស្ការ ចំពោះព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមកស្សប ព្រះអង្គរួចផុតស្រឡះ ចាកកិលេសទាំងពួងហើយ។ សូមនមស្ការ ចំពោះព្រះសម្មាសម្ពុទ្ធ ជាសក្យបុត្ត ទ្រង់មានព្រះកាយផ្សាយចេញនូវព្រះរស្មី ទ្រង់មានសិរី ដែលសំដែងធម៌នេះ ជាគ្រឿងបន្ទោបង់សេចក្តីទុក្ខទាំងពួង។ មួយទៀត ព្រះសម្មាសម្ពុទ្ធទាំងឡាយ អង្គណា ព្រះអង្គរលត់កិលេសហើយ ទ្រង់ឃើញច្បាស់នូវធម៌តាមសេចក្តីពិត ក្នុងលោក ព្រះសម្មាសម្ពុទ្ធទាំងនោះ ជាព្រះឲីណាស្រព ព្រះអង្គមិនមានសេចក្តីញុះញង់ស៊កសៀត (ទ្រង់ប្រសើរដោយគុណ) មិនក្លៀវក្លា (ដោយកិលេស)។ ទេវតា និងមនុស្សទាំងឡាយ តែងនមស្ការព្រះសម្មាសម្ពុទ្ធ ជាគោតមគោត្រ ព្រះអង្គជា

ប្រយោជន៍ ដល់ទេវតា និងមនុស្សទាំងឡាយ ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ទ្រង់ប្រសើរដោយគុណ ព្រះអង្គឥតមានសេចក្តីព្រឺស្ញើប។

[៨១] ព្រះអាទិត្យ មានរស្មីដ៏ភ្លឺរក្សារ រះឡើងអំពីទិសណា មានមណ្ឌលធំ (ក្នុងទីនោះ) កាលព្រះអាទិត្យរះឡើងហើយ រាត្រីក៏បាត់ទៅ។ មួយទៀត កាលព្រះអាទិត្យរះឡើងហើយ មហាជន នាំគ្នាហៅថាថ្ងៃ សូម្បីអន្លង់ទឹក ក្នុងទីដែលព្រះអាទិត្យរះឡើងនោះ ជាសមុទ្រដ៏ជ្រៅ មានទឹកហូរទៅ (ពីទីផ្សេងៗ) ជនទាំងឡាយ តែងសម្គាល់នូវអន្លង់ទឹកនោះ ត្រង់កន្លែងដែលព្រះអាទិត្យរះឡើងនោះ ថាជាសមុទ្រ មានទឹកហូរទៅយ៉ាងនេះ។ ស្តេចជាធំ ដ៏ទ្រង់យស ទ្រង់រក្សាទិសណា មហាជន តែងហៅទិសនោះ ថាបុរិមទិស អំពីភ្នំសិនេរុនោះ ទ្រង់ជាអធិបតី លើគន្ធព្វទាំងឡាយ មានព្រះនាមថា ធតរដ្ឋ មានពួកគន្ធព្វហែហម ទ្រង់ត្រេកត្រអាលដោយរបាំ និងចម្រៀង។ ព្រះរាជបុត្រ របស់ស្តេចជាធំនោះ មានច្រើនដល់ម៉្លោះ ខ្ញុំព្រះអង្គបានស្តាប់មកថា មាននាមដូចៗគ្នា ព្រះរាជបុត្តទាំង៩១ព្រះអង្គ សឹងមាននាមថាឥន្ទៈ មានកំឡាំងច្រើន ឯព្រះរាជបុត្តទាំងនោះ ឃើញព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ភ្ញាក់អំពីការដេកលក់ គឺអវិជ្ជា ទ្រង់ប្រសើរ (ដោយគុណ) ឥតមានសេចក្តីព្រឺស្ញើប ក៏នមស្ការអំពីចម្ងាយ។ បពិត្រព្រះអង្គ ជាបុរសអាជានេយ្យ ខ្ញុំព្រះអង្គសូមនមស្ការ ចំពោះព្រះអង្គ បពិត្រព្រះអង្គជាបុរសខ្ពង់ខ្ពស់ ខ្ញុំព្រះអង្គសូមនមស្ការ ចំពោះព្រះអង្គ សូម្បីអមនុស្សទាំងឡាយ ក៏រមែងថ្វាយបង្គំព្រះអង្គថា ព្រះអង្គទតព្រះនេត្រមើលមហាជន ដោយសព្វញ្ញុតញ្ញាណដ៏ផូរផង់។ ពួកខ្ញុំព្រះអង្គបានស្តាប់មកយ៉ាងនេះរឿយៗ ព្រោះហេតុនោះ ពួកខ្ញុំព្រះអង្គតែងនិយាយយ៉ាងនេះថា អ្នកទាំងឡាយ ថ្វាយបង្គំព្រះជិនស្រី ដែលជាគោតមគោត្របូ (ព្រះរាជបុត្តទាំងនោះ តបថា) យើងខ្ញុំទាំងឡាយ ថ្វាយបង្គំព្រះជិនស្រី ជាគោតមគោត្រ យើងខ្ញុំទាំងឡាយថ្វាយបង្គំព្រះពុទ្ធគោតមគោត្រ ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ។

[៨២] ជនជាអ្នកមានពាក្យញុះញង់ ស៊កសៀត ជាអ្នកតិះដៀលគេ ក្នុងទីកំបាំងមុខ ដូចជាជនអ្នកស៊ីសាច់ខ្នង ជាអ្នកសម្លាប់សត្វ ជាអ្នកធ្វើអំពើអាក្រក់ ជាចោរ ជាមនុស្សមានកល លល្បួង ជនទាំងនោះ លុះធ្វើកាលកិរិយាទៅហើយ គេតែងថា (ឲ្យនាំទៅ) តាមទិសណា ។ ស្តេចជាធំទ្រង់យស ទ្រង់រក្សានូវទិសណា មហាជន តែងនាំគ្នាហៅទិសនោះថា ទក្ខិណាទិស (រាប់) អំពីភ្នំសិនេរុមក ស្តេចនោះ ជាអធិបតី លើកុម្ភណ្ឌទាំងឡាយ ទ្រង់ព្រះនាម វិរុឡ្ហៈ ដែលមានពួកកុម្ភណ្ឌចោមរោមហើយ ទ្រង់ត្រេកអរដោយរបាំ និងចម្រៀងទាំងឡាយ។ ព្រះរាជបុត្តរបស់ស្តេចនោះ មានច្រើនក៏មែន តែខ្ញុំព្រះអង្គបានស្តាប់មកថា មានព្រះនាមដូចៗគ្នា ព្រះរាជបុត្តទាំង៩១ព្រះអង្គ សុទ្ធតែមានព្រះនាមថាឥន្ទៈ ទ្រង់មានកំឡាំងច្រើន ក៏ឯព្រះរាជបុត្តទាំងនោះ ឃើញព្រះអាទិច្ចវង្សព្រះអង្គភ្ញាក់ហើយ អំពីការដេកលក់ គឺអវិជ្ជា ទ្រង់ប្រសើរ (ដោយគុណ) ឥតមានសេចក្តីព្រឺស្ញើប ក៏នមស្ការអំពីចម្ងាយ ។ បពិត្រព្រះអង្គ ជាបុរសអាជានេយ្យ ខ្ញុំព្រះអង្គសូមនមស្ការ ចំពោះព្រះអង្គ បពិត្រព្រះអង្គ ជាបុរសឧត្តម ខ្ញុំព្រះអង្គសូមនមស្ការ ចំពោះព្រះអង្គ សូម្បីអមនុស្សទាំងឡាយ ក៏រមែងថ្វាយបង្គំព្រះអង្គថា ព្រះអង្គទតព្រះនេត្រមើលមហាជន ដោយសព្វញ្ញុតញ្ញាណដ៏ផូរផង់។ ខ្ញុំព្រះអង្គ បានស្តាប់មកយ៉ាងនេះរឿយៗ ព្រោះហេតុនោះ ពួកខ្ញុំព្រះអង្គនិយាយយ៉ាងនេះថា អ្នកទាំងឡាយ នមស្ការចំពោះព្រះជិនស្រី ជាគោតមគោត្រឬ (ព្រះរាជបុត្តទាំងនោះ តបថា) យើងខ្ញុំទាំងឡាយ ថ្វាយបង្គំព្រះជិនស្រី ជាគោតមគោត្រ យើងខ្ញុំទាំងឡាយ ថ្វាយបង្គំព្រះសម្ពុទ្ធ ជាគោតមគោត្រ ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ។

[៨៣ ] ព្រះអាទិត្យ មានរស្មីដ៏ក្លៀវក្លា អស្តង្គតទៅក្នុងទីណា មានមណ្ឌលដ៏ធំ ក្នុងទីនោះ កាលដែលព្រះអាទិត្យអស្តង្គតទៅហើយ ពេលថ្ងៃក៏បាត់ទៅ កាលបើព្រះអាទិត្យអស្តង្គតទៅហើយ មហាជន នាំគ្នាហៅថាយប់។ សូម្បីអន្លង់ទឹក ត្រង់កន្លែងដែលព្រះ

អាទិត្យអស្តង្គតនោះ ជាសមុទ្រដ៏ជ្រៅ មានទឹកហូរទៅ ជនទាំងឡាយ តែងសម្គាល់នូវអន្លង់ទឹកនោះ ត្រង់កន្លែងដែលព្រះអាទិត្យអស្តង្គតនោះ ថាជាសមុទ្រ មានទឹកហូរទៅយ៉ាងនេះ ។ ស្តេចជាធំ ទ្រង់យស ទ្រង់រក្សាទិសណា មហាជន តែងហៅទិសនោះ ថាបច្ឆិមទិស អំពីភ្នំសិនេរុមក ស្តេចជាធំនោះ ជាអធិបតី លើនាគទាំងឡាយ ទ្រង់ព្រះនាមថា វិរូបក្ខៈ ដែលមានពួកនាគចោមរោមហើយ ទ្រង់ត្រេកអរ ដោយពួករបាំ និងចម្រៀង។ ព្រះរាជបុត្តទាំងឡាយ របស់ស្តេចវិរូបក្ខៈនោះ មានច្រើនក៏មែន តែខ្ញុំព្រះអង្គបានស្តាប់មកថា មានឈ្មោះដូចៗគ្នា ព្រះរាជបុត្តទាំង៩១ព្រះអង្គ ក៏ព្រះនាមថាឥន្ទៈ សុទ្ធតែមានកំឡាំងច្រើន ឯព្រះរាជបុត្តទាំងនោះ លុះឃើញព្រះសម្ពុទ្ធ ជាអាទិច្ចវង្ស ទ្រង់ក្វាក់ហើយ ចាកការដេកលក់ គឺអវិជ្ជា ទ្រង់ប្រសើរ (ដោយគុណ) ឥតមានសេចក្តីព្រឺស្ញើប ក៏នាំគ្នានមស្ការអំពីចម្ងាយ ។ បពិត្រព្រះអង្គ ជាបុរសអាជានេយ្យ ខ្ញុំព្រះអង្គសូមនមស្ការ ចំពោះព្រះអង្គ បពិត្រព្រះអង្គ ជាបុរសដ៏ខ្ពង់ខ្ពស់ ខ្ញុំព្រះអង្គសូមនមស្ការ ចំពោះព្រះអង្គ សូម្បីអមនុស្សទាំងឡាយ ក៏រមែងថ្វាយបង្គំព្រះអង្គថា ទ្រង់ទតព្រះនេត្រមើលមហាជន ដោយសព្វញ្ញុតញ្ញាណដ៏ផូរផង់ ។ ពួកខ្ញុំព្រះអង្គ បានស្តាប់មកយ៉ាងនេះរឿយៗ ព្រោះហេតុនោះ ខ្ញុំព្រះអង្គតែងនិយាយយ៉ាងនេះថា អ្នកទាំងឡាយ នមស្ការព្រះជិនស្រីជាគោតមគោត្របុ (ព្រះរាជបុត្តទាំងនោះ តបថា) យើងខ្ញុំទាំងឡាយ នមស្ការចំពោះព្រះជិនស្រី ជាគោតមគោត្រ យើងខ្ញុំទាំងឡាយ នមស្ការព្រះពុទ្ធ ជាគោតមគោត្រ ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ។

[៨៤] ឧត្តរកុរុទ្វីប ជាទីរីករាយ មានភ្នំសិនេរុដ៏ធំ គួរជាទីមើល តាំងនៅក្នុងទីណា ពួកមនុស្សកើតក្នុងឧត្តរកុរុទ្វីបនោះ ឥតមានប្រកាន់របស់អ្វីថា ជារបស់ខ្លួនឡើយ ។ មនុស្សទាំងអម្បាលនោះ មិនចាំបាច់ព្រោះពូជ មិនចាំបាច់នាំនង្គ័លចេញទៅ (ដោយគិតថា អាត្មាអញនឹងភ្ជួរក្នុងទីនោះ ។) បរិភោគតែស្រូវសាលី ដែលកើតឯងក្នុងព្រៃ ជាស្រូវ

មិនមានកុណ្ឌក មិនមានអង្កាម ស្អាត មានក្លិនក្រអូប ផ្លែចេញជាអង្ករ មនុស្សទាំងឡាយដាក់អង្ករនោះក្នុងឆ្នាំង ចំអិនដោយភ្លើងឥតផ្សែង មិនមានរងើក ទើបនាំគ្នាបរិភោគភោជនអំពីឆ្នាំងនោះ ។ មនុស្សទាំងនោះ ទឹមនូវមេគោមានក្រចកតែមួយ (ដូចក្រចកសេះ) បរទៅសព្វទិស ទឹមបសុសត្វ (សត្វជើងបួនក្រៅពីមេគោ) មានក្រចកតែមួយ បរទៅសព្វទិស។ យកស្រីធ្វើជាវាហនៈ ត្រាច់ទៅសព្វទិស យកបុរសធ្វើជាវាហនៈ ត្រាច់ទៅសព្វទិស។ យកកុមារី ធ្វើជាវាហនៈ ត្រាច់ទៅសព្វទិស យកកុមារធ្វើជាវាហនៈ ហើយត្រាច់ទៅសព្វទិស។ មនុស្សទាំងអម្បាលនោះ នាំគ្នាឡើងយាន ត្រាច់ទៅក្នុងទិសទាំងពួងពួកស្រីទាំងឡាយ ជាអ្នកបម្រើស្តេចនោះ ។ យានដំរី យានសេះ យានជាទិព្វ [យានជាទិព្វមានច្រើនយ៉ាង កើតប្រាកដ ដល់ពួកជនទាំងនោះ ប្រសិនណាជាជនទាំងនោះអង្គុយត្រង់ទីដំណេក ឬលើតាំង លើវរ (គ្រែស្នែង) ជាដើម ក៏ចរទៅបាន ។ យាននេះកើតសម្រាប់ស្តេចដែលមានបុណ្យ មាន អានុភាពម្តងៗ ឬសម្រាប់ទេវតាប៉ុណ្ណោះ (អដ្ឋកថា) ។] ប្រាសាទ និងវរ ក៏មានសម្រាប់ស្តេច ជាធំដ៏ទ្រង់យស។ មួយទៀត ស្តេចនោះ ទ្រង់កសាងនគរទុក ក្នុងអាកាស គឺអាដានាដានគរ កុសិនាដានគរ បរកុសិនាដានគរ នាដបរិយានគរ បរកុសិតនាដានគរ។ សាងនគរឈ្មោះ កបិវន្តក្នុងទិសខាងជើង ក្នុងចំណែកទិសដទៃទៀត បានសាងនគរឈ្មោះជនោឃៈ ឈ្មោះនវនវតិយៈ ឈ្មោះអម្ពរអម្ពរវតិយៈ និងរាជធានី ឈ្មោះ អាឡកមន្ទា បពិត្រព្រះអង្គ អ្នកនិទ៌ុក្ខ ស្តេចជាធំឈ្មោះកុវេរៈ មានរាជធានីឈ្មោះវិសាណា ព្រោះហេតុនោះ ស្តេចជាធំ ទ្រង់ព្រះនាមកុវេរៈ មហាជននាំគ្នាហៅថា វេស្សវ័ណ ។ ពួកយក្ខឈ្មោះ តតោលា តត្តលា តតោតលា ឱជសី តេជសី តតោជសី សុរោ រាជា សុរោរាជា អរិដ្ឋ នេមិ អរិដ្ឋនេមិ តែងត្រួតត្រា ប្រកាសនូវប្រយោជន៍ផ្សេងៗ។ មួយទៀត ភ្លៀងនាំទឹកអំពីស្រះបោក្ខរណីណា ហើយបង្អុរចុះ ភ្លៀងហូរចេញអំពីទីណា ត្រង់ទីនោះឯង មានអន្លង់ទឹក ឈ្មោះធរណី ពួកយក្ខតែងអង្គុយប្រជុំគ្នាក្នុងទីណា ត្រង់ទីនោះឯង មានសភា ឈ្មោះភគលវតី។ ត្រង់ទីនោះ មានដើមឈើផ្លែជានិច្ច ដេរដាស

ដោយហ្វូងបក្សីផ្សេងៗ កងរំពងដោយសំឡេងសត្វក្ងោក សត្វក្រៀល (ព្រមទាំង) ពួកតាវ៉ៅមានសំឡេងពីរោះ ។ សំឡេងបក្សី ឈ្មោះជីវញ្ជីវក ក៏មានក្នុងទីនុ៎ះ មួយទៀត ពួកបក្សីឈ្មោះឱដ្ឋវចិត្តក: ហ្វូងមាន់ព្រៃ ក្ដាម និងហ្វូងសត្វបោក្ខរសាតក: ក៏អាស្រ័យនៅក្នុងត្រពាំងឈូក ។ ម្យ៉ាងទៀត សំឡេងសត្វសេក និងសារិកា ក៏មានក្នុងទីនោះ មានទាំងពួកបក្សី ឈ្មោះទណ្ឌមានវក: ស្រះឈូករបស់ស្ដេចកុវេរ:នោះ ជាស្រះល្អសព្វកាលឥតចន្លោះ ។ ស្ដេចជាធំ ទ្រង់យស ទ្រង់អភិបាលទិសណា មហាជនតែងនាំគ្នាហៅទិសនោះថា ឧត្តរទិស រាប់អំពីភ្នំសិនេរុមក ។ ព្រះអង្គជាអធិបតីលើពួកយក្ខ ទ្រង់ព្រះនាមថា កុវេរ: ដែលមានពួកយក្ខចោមរោមហើយ ទ្រង់ត្រេកត្រអាលដោយពួករបាំ និងចម្រៀងៗ ពួកព្រះរាជបុត្ររបស់ព្រះអង្គ ក៏មានច្រើន តែខ្ញុំព្រះអង្គបានស្ដាប់មកថា មានព្រះនាមដូចៗគ្នា ព្រះរាជបុត្រទាំង៩១ព្រះអង្គ មានព្រះនាមថា ឥន្ទ: ទ្រង់មានកំឡាំងច្រើន ។ ឯព្រះរាជបុត្រទាំងនោះ លុះបានឃើញព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ភ្ញាក់ហើយ ចាកការដេកលក់ គឺអវិជ្ជា ប្រសើរ (ដោយគុណ) ឥតមានសេចក្ដីព្រឺស្ញើប ក៏នាំគ្នានមស្ការអំពីចម្ងាយ ។ បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំព្រះអង្គ សូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គជាបុរសឧត្តម ខ្ញុំព្រះអង្គ សូមនមស្ការ ចំពោះព្រះអង្គ សូម្បីអមនុស្សទាំងឡាយ ក៏រមែងថ្វាយបង្គំព្រះអង្គថា ព្រះអង្គទតព្រះនេត្រមើលមហាជន ដោយសព្វញ្ញុតញ្ញាណដ៏ផូរផង់ ។ ពួកខ្ញុំព្រះអង្គ បានស្ដាប់មកយ៉ាងនេះរឿយៗ ព្រោះហេតុនោះ ពួកខ្ញុំព្រះអង្គតែងនិយាយយ៉ាងនេះថា អ្នកទាំងឡាយ នមស្ការចំពោះព្រះជិនស្រី ជាគោតមគោត្របុ្ត ព្រះរាជបុត្រទាំងនោះ តបថា យើងទាំងឡាយ នមស្ការចំពោះព្រះជិនស្រី ជាគោតមគោត្រ យើងទាំងឡាយ នមស្ការចំពោះព្រះពុទ្ធ ជាគោតមគោត្រ ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណ:ៗ

[៨៥] បពិត្រព្រះអង្គទ្រង់និទ៌ុក្ខ ការរក្សាជាប់ទាក់ទងក្នុងអាដានាដានគរនេះឯង រមែងប្រព្រឹត្តទៅ ដើម្បីគ្រប់គ្រងរក្សា ដើម្បីមិនបៀតបៀន ដើម្បីនៅសប្បាយ ដល់ពួកភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកា។ ការរក្សាជាប់ទាក់ទងក្នុងអាដានាដានគរនេះ ដែលបុគ្គលណាមួយ ទោះបីជាភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកា រៀនដោយប្រពៃ រៀនដោយសព្វគ្រប់ ជំរះអត្ថ និងព្យញ្ជនៈឲ្យបរិបូណ៌ បើអមនុស្ស ទោះបីជាយក្ខក្តី យក្ខិនីក្តី កូនប្រុសរបស់យក្ខក្តី កូនស្រីរបស់យក្ខក្តី អមាត្យធំរបស់យក្ខក្តី បរិស័ទរបស់យក្ខក្តី អ្នកបំរើរបស់យក្ខក្តី គន្ធព្វប្រុសក្តី គន្ធព្វស្រីក្តី កូនប្រុសរបស់គន្ធព្វក្តី កូនស្រីរបស់គន្ធព្វក្តី អមាត្យធំរបស់គន្ធព្វក្តី បរិស័ទរបស់គន្ធព្វក្តី អ្នកបំរើរបស់គន្ធព្វក្តី កុម្ភណ្ឌប្រុសក្តី កុម្ភណ្ឌស្រីក្តី កូនប្រុសរបស់កុម្ភណ្ឌក្តី កូនស្រីរបស់កុម្ភណ្ឌក្តី អមាត្យធំរបស់កុម្ភណ្ឌក្តី បរិស័ទរបស់កុម្ភណ្ឌក្តី អ្នកបំរើរបស់កុម្ភណ្ឌក្តី នាគឈ្មោលក្តី នាគញីក្តី កូនឈ្មោលរបស់នាគក្តី កូនញីរបស់នាគក្តី អមាត្យធំរបស់នាគក្តី បរិស័ទរបស់នាគក្តី អ្នកបំរើរបស់នាគក្តី ដែលជាអ្នកមានចិត្តប្រទូស្ត នូវបុគ្គលនោះ ហើយដើរតាមភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកា ដែលកំពុងដើរ ឬឈរជិតភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកា ដែលកំពុងឈរ ឬអង្គុយជិតភិក្ខុ ភិក្ខុនី ឧបាសក និងកបាសិកា ដែលកំពុងអង្គុយ ឬដេកជិតភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកា ដែលកំពុងដេក។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ អមនុស្សនោះ មិនគប្បីបានសក្ការៈ និងសេចក្តីគោរពក្នុងស្រុក ឬនិគមទាំងឡាយនៃខ្ញុំឡើយ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ អមនុស្សនោះមិនគប្បីបានទីផ្ទះ ឬការនៅជានិច្ចក្នុងរាជធានីឈ្មោះ អាលកមន្ទារបស់ខ្ញុំឡើយ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ អមនុស្សនោះ មិនគប្បីបានចូលកាន់ទីប្រជុំរបស់ពួកយក្ខទាំងឡាយ នៃខ្ញុំឡើយ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ មួយទៀត អមនុស្សទាំងឡាយ មិនគប្បីធ្វើអាវាហមង្គល ឬវិវាហមង្គល និងអមនុស្សនោះទេ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ អមនុស្សទាំងឡាយ គប្បីផ្តាសាអមនុស្សនោះ ដោយពាក្យផ្តាសាទាំងឡាយ ពេញបន្ទុកប្រៀបធៀបដោយខ្លួន (អាក្រក់)។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ

អមនុស្សទាំងឡាយ គប្បីផ្គាប់បាត្រទទេលើក្បាលនៃអមនុស្សនោះ ។ មួយទៀត អមនុស្សទាំងឡាយ គប្បីបំបែកក្បាលអមនុស្សនោះជា៧ ភាគ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ មានអមនុស្សទាំងឡាយ ក្រោធពិរោធក្រៃលែងជាងហេតុ អមនុស្សទាំងឡាយនោះ មិនធ្វើតាមអាជ្ញានៃស្តេចជាធំ មិនធ្វើតាមអាជ្ញានៃយក្ខ ជាសេនាបតី ២៨ នាក់ របស់ស្តេចជាធំនោះ ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ អមនុស្សទាំងឡាយនោះ ៗឯង គេតែងហៅថា ជាសត្រូវនឹងស្តេចជាធំ ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ពួកចោរក្នុងដែននៃស្តេចមគធៈ មិនធ្វើតាមអាជ្ញានៃស្តេចមគធៈ មិនធ្វើតាមអាជ្ញានៃសេនាបតី របស់ស្តេចមគធៈ មិនធ្វើតាមអាជ្ញានៃសេនាបតី ជាអ្នកប្រៀនប្រដៅរបស់ស្តេចមគធៈ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ពួកមហាចោរទាំងអម្បាលនោះ គេតែងហៅថាជាសត្រូវនឹងស្តេចមគធៈ យ៉ាងណាមិញ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ មានអមនុស្សទាំងឡាយ ជាអ្នកក្រោធពិរោធក្រៃលែងជាងហេតុ អមនុស្សទាំងនោះ មិនធ្វើតាមអាជ្ញានៃស្តេចជាធំ មិនធ្វើតាមអាជ្ញានៃសេនាបតីរបស់ស្តេចជាធំ មិនធ្វើតាមអាជ្ញាពួកយក្ខសេនាបតី ជាអ្នកប្រៀនប្រដៅរបស់ស្តេចជាធំ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ អមនុស្សទាំងឡាយនោះ ៗឯង គេតែងហៅថា ជាសត្រូវនឹងស្តេចជាធំ យ៉ាងដូច្នោះឯង ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ប្រសិនបើអមនុស្សណាមួយ ជាយក្ខប្រុសក្តី យក្ខស្រីក្តី កូនប្រុសរបស់យក្ខក្តី កូនស្រីរបស់យក្ខក្តី មហាមាត្ររបស់យក្ខក្តី បរិស័ទរបស់យក្ខក្តី អ្នកបំរើរបស់យក្ខក្តី គន្ធព្វប្រុសក្តី គន្ធព្វស្រីក្តី កូនប្រុសរបស់គន្ធព្វក្តី កូនស្រីរបស់គន្ធព្វក្តី មហាមាត្យរបស់គន្ធព្វក្តី បរិស័ទរបស់គន្ធព្វក្តី អ្នកបំរើរបស់គន្ធព្វក្តី កុម្ភណ្ឌប្រុសក្តី កុម្ភណ្ឌស្រីក្តី កូនប្រុសរបស់កុម្ភណ្ឌក្តី កូនស្រីរបស់កុម្ភណ្ឌក្តី មហាមាត្យរបស់កុម្ភណ្ឌក្តី បរិស័ទរបស់កុម្ភណ្ឌក្តី អ្នកបំរើរបស់កុម្ភណ្ឌក្តី នាគឈ្មោលក្តី នាគញីក្តី កូនឈ្មោលរបស់នាគក្តី កូនញីរបស់នាគក្តី មហាមាត្យរបស់នាគក្តី បរិស័ទរបស់នាគក្តី អ្នកបំរើរបស់នាគក្តី ជាអ្នកមានចិត្តប្រទូស្ត ដើរទៅតាមភិក្ខុ ឬភិក្ខុនី ឧបាសក ឧបាសិកា ដែលកំពុងដើរ ឬឈរជិតភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ដែលកំពុងឈរ ឬអង្គុយជិតភិក្ខុ ភិក្ខុនី

ឧបាសក ឧបាសិកា ដែលកំពុងអង្គុយ ឬដេកជិតភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ដែលកំពុងដេក។ អមនុស្សនោះ ត្រូវបុគ្គលពោលទោស កន្ទក់កន្ទេញ ត្រូវស្រែកប្តឹងដល់ពួកយក្ស ពួកយក្ខជាធំ ពួកសេនាបតី ពួកសេនាបតីជាធំ ទាំងអម្បាលនេះថា យក្ខនេះចាប់គេ យក្ខនេះចូលគេ យក្ខនេះបៀតបៀនគេ យក្ខនេះបៀតបៀនផ្សេងៗ យក្ខនេះធ្វើទុក្ខគេ យក្ខនេះធ្វើឲ្យគេលំបាក យក្ខនេះមិនលែងគេ។

[៨៦] ដល់ពួកយក្ខ ពួកមហាយក្ខ ពួកសេនាបតី ពួកមហាសេនាបតី ដូចម្តេចខ្លះ។

យក្ខឈ្មោះឥន្ទ:១ សោម:១ វរុណ:១ ភារទ្វាជ:១ បជាបតិ១ ចន្ទន:១ កាមសេដ្ឋ:១ កិន្នុឃណ្ឌុ១ និឃណ្ឌុ១ ។ បនាទ:១ ឱបមញ្ញ:១ ទេវសូត:១ មាតលិ១ អតិចសេន:១ គន្ធព្វ:១ នឡោរាជ:១ ជនោសភ:១ ។ សាតាគិរ:១ ហេមវត:១ បុណ្ណក:១ ករតិយ:១ គុល:១ សិវក:១ មុចលិន្ទ:១ វេស្សាមិត្ត:១ យុគន្ធរ:១ ។ គោបាល:១ សុប្បគេធ:១ ហិរិ១ នេត្តិ១ មន្ទិយ:១ បញ្ចាលចន្ទ:១ អាឡវក:១ បជុណ្ណ:១ សុមុខ:១ ទធិមុខ:១ មណិ១ មានិចរ:១ ទីឃ:១ សេរិសក:១ ។

[៨៧] ត្រូវពោលទោស កន្ទក់កន្ទេញ ត្រូវស្រែកប្តឹងដល់ពួកយក្ស ពួកមហាយក្ខ ពួកសេនាបតី ពួកមហាសេនាបតី ទាំងអម្បាលនេះថា យក្ខនេះចាប់គេ យក្ខនេះចូលគេ យក្ខនេះបៀតបៀនគេ យក្ខនេះបៀតបៀនផ្សេងៗ យក្ខនេះធ្វើទុក្ខគេ យក្ខនេះធ្វើឲ្យគេលំបាក យក្ខនេះមិនលែងគេ។

[៨៨] បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ការរក្សាជាប់តមកអំពី អាដានាដានគាថានេះឯង ប្រព្រឹត្តទៅដើម្បីគ្រប់គ្រងរក្សា ដើម្បីមិនបៀតបៀនគ្នា ដើម្បីនៅជាសុខដល់ពួកភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកា។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ណ្ហើយឥឡូវនេះ ពួកខ្ញុំព្រះអង្គមានរវល់ច្រើន មានកិច្ចគួរធ្វើច្រើន ខ្ញុំព្រះអង្គសូមក្រាបថ្វាយបង្គំលា។ ព្រះមានព្រះភាគ

ទ្រង់ត្រាស់ថា បពិត្រមហារាជទាំងឡាយ ចូរព្រះអង្គកំណត់កាលគួរ ក្នុងកាលឥឡូវនេះចុះ ។

[៨៩] លំដាប់នោះ ស្តេចធំទាំង៤អង្គ ក្រោកចាកអាសនៈថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយ ក៏បាត់ទៅក្នុងទីនោះឯង។ យក្ខទាំងអម្បាលនោះ លុះក្រោកចាកអាសនៈហើយ ពួកខ្លះថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយ ក៏បាត់ទៅក្នុងទីនោះ ពួកខ្លះគ្រាន់តែពោលពាក្យរាក់ទាក់សំណេះសំណាល ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏បាត់ទៅក្នុងទីនោះ ពួកខ្លះ គ្រាន់តែប្រណម្យអញ្ជលី ចំពោះព្រះមានព្រះភាគហើយ ក៏បាត់ទៅក្នុងទីនោះ ពួកខ្លះគ្រាន់តែប្រកាសនាម និងគោត្រ របស់ខ្លួន ហើយក៏បាត់ទៅក្នុងទីនោះ ពួកខ្លះ គ្រាន់តែនៅស្ងៀមហើយ ក៏បាត់ទៅក្នុងទីនោះ ។

[៩០] លុះកន្លងរាត្រីនោះទៅហើយ ទើបព្រះមានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ យប់មិញ ពួកស្តេចធំទាំង៤ តាំងការរក្សាក្នុងទិសទាំង៤ តាំងពលទុកក្នុងទិសទាំង៤ តាំងអ្នកត្រួតត្រាទុកក្នុងទិសទាំង៤ ដោយសេនាយក្ខដ៏ច្រើន សេនាគន្ធព្វដ៏ច្រើន សេនាកុម្ភណ្ឌដ៏ច្រើន សេនានាគដ៏ច្រើន លុះវេលារាត្រីកន្លងទៅហើយ ស្តេចទាំងនោះ មានពន្លឺរុងរឿង ញុំាងភ្នំគិជ្ឈកូដទាំងមូលឲ្យភ្លឺស្វាងហើយ ក៏នាំគ្នាចូលមករកតថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំតថាគត អង្គុយក្នុងទីដ៏សមគួរ។ ម្នាលភិក្ខុទាំងឡាយ យក្ខទាំងអម្បាលនោះឯង ពួកខ្លះថ្វាយបង្គំតថាគត ហើយអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះ គ្រាន់តែពោលពាក្យរាក់ទាក់សំណេះសំណាល ជាមួយនឹងតថាគត លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ពួកខ្លះ គ្រាន់តែប្រណម្យអញ្ជលី ចំពោះតថាគត អង្គុយក្នុងទីដ៏សមគួរ ពួកខ្លះ គ្រាន់តែប្រកាសនាម និងគោត្រ អង្គុយក្នុងទីដ៏សមគួរ ពួកខ្លះ គ្រាន់តែអង្គុយស្ងៀមៗ

ក្នុងទីដ៏សមគួរ។ ម្នាលភិក្ខុទាំងឡាយ ស្ដេចជាធំទ្រង់ព្រះនាមវេស្សវ័ណ លុះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ពោលពាក្យនឹងតថាគតយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ពួកយក្ខជាន់ខ្ពស់ មិនជ្រះថ្លាចំពោះព្រះមានព្រះភាគ ក៏មាន បពិត្រព្រះអង្គដ៏ចំរើន ពួកយក្ខជាន់ខ្ពស់ ជ្រះថ្លាចំពោះព្រះមានព្រះភាគ ក៏មាន បពិត្រព្រះអង្គដ៏ចំរើន ពួកយក្ខជាន់កណ្ដាលខ្លះ មិនជ្រះថ្លាចំពោះព្រះមានព្រះភាគ ក៏មាន បពិត្រព្រះអង្គដ៏ចំរើន ពួកយក្ខជាន់កណ្ដាល ជ្រះថ្លាចំពោះព្រះមានព្រះភាគ ក៏មាន បពិត្រព្រះអង្គដ៏ចំរើន ពួកយក្ខជាន់ទាប មិនជ្រះថ្លាចំពោះព្រះមានព្រះភាគ ក៏មាន បពិត្រព្រះអង្គដ៏ចំរើន ពួកយក្ខជាន់ទាប ជ្រះថ្លាចំពោះព្រះមានព្រះភាគ ក៏មាន បពិត្រព្រះអង្គដ៏ចំរើន ឯយក្ខដែលមិនជ្រះថ្លា ចំពោះព្រះមានព្រះភាគ មានច្រើនណាស់ ព្រោះហេតុអ្វី បពិត្រព្រះអង្គដ៏ចំរើន ព្រោះថាព្រះមានព្រះភាគ ទ្រង់សំដែងធម៌ ដើម្បីឲ្យវៀរចាកបាណាតិបាត ទ្រង់សំដែងធម៌ ដើម្បីឲ្យវៀរចាកអទិន្នាទាន ទ្រង់សំដែងធម៌ ដើម្បីឲ្យវៀរចាកកាមេសុមិច្ឆាចារ ទ្រង់សំដែងធម៌ ដើម្បីឲ្យវៀរចាកមុសាវាទ ទ្រង់សំដែងធម៌ ដើម្បីឲ្យវៀរចាកទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្ដីប្រមាទ។ បពិត្រព្រះអង្គដ៏ចំរើន ប៉ុន្ដែយក្ខទាំងឡាយច្រើនណាស់ ដែលមិនវៀរចាកបាណាតិបាត មិនវៀរចាកអទិន្នាទាន មិនវៀរចាកកាមេសុមិច្ឆាចារ មិនវៀរចាកមុសាវាទ មិនវៀរចាកទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្ដីប្រមាទសោះ (ព្រោះហេតុនោះ) អំពើវៀរនោះ មិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់យក្ខទាំងឡាយនោះ បពិត្រព្រះអង្គដ៏ចំរើន មានសាវ័ករបស់ព្រះមានព្រះភាគ អាស្រ័យនៅសេនាសនៈស្ងាត់ ដែលតាំងនៅក្នុងព្រៃ មានសូរសព្ទតិចតួច មានសំលេងគឹកកងតិច ប្រាសចាកសំដីរបស់មនុស្សអ្នកដើរទៅមក សមគួរដល់ការកំបាំងអំពីពួកមនុស្ស គួរជាទីលាក់ខ្លួនពួន អាត្មាបាន ពួកយក្ខជាន់ខ្ពស់តែងនៅជានិច្ច ក្នុងព្រៃនោះក៏មាន បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ទ្រង់បង្រៀនព្រះបរិត្តសម្រាប់រក្សាក្នុងអាដានាដានគរ ដើម្បីឲ្យពួកយក្ខដែលមិនទាន់ជ្រះថ្លា ក្នុងសាសនាព្រះមានព្រះភាគនេះ បានជ្រះថ្លា

ឡើង ដើម្បីការគ្រប់គ្រងរក្សា ដើម្បីមិនបៀតបៀនគ្នា ដើម្បីនៅជាសុខដល់ភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកា។ ម្នាលភិក្ខុទាំងឡាយ តថាគត បានទទួលនិមន្តដោយតុណ្ហីភាព ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង ស្តេចជាធំឈ្មោះវេស្សវណ្ណ ជ្រាបច្បាស់នូវតថាគតទទួលនិមន្តហើយ ក៏ប្រកាសព្រះបរិត្តសម្រាប់រក្សា ក្នុងអាដានាដានគារនេះ ក្នុងវេលានោះថា

[៩១] សូមនមស្ការចំពោះព្រះពុទ្ធ ទ្រង់ព្រះនាមវិបស្សី ព្រះអង្គមានចក្ខុ ព្រះអង្គមានសិរី សូមនមស្ការចំពោះព្រះពុទ្ធ ទ្រង់ព្រះនាមសិខី ព្រះអង្គមានសេចក្តីអនុគ្រោះដល់សត្វទាំងពួងជាប្រក្រតី។បេ។

(បេយ្យាលៈ ដែលមានហើយ ក្នុងខាងដើមនោះឯង បណ្ឌិត គប្បីឲ្យពិស្តារចុះ)។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ការរក្សាជាប់ទាក់ទង ក្នុងអាដានាដានគារនេះ ប្រព្រឹត្តទៅ ដើម្បីគ្រប់គ្រងរក្សា ដើម្បីមិនបៀតបៀនគ្នា ដើម្បីនៅជាសុខ ដល់ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ឥឡូវនេះ ពួកខ្ញុំព្រះអង្គមានរវល់ច្រើន មានកិច្ចគួរធ្វើច្រើន ខ្ញុំព្រះអង្គសូមថ្វាយបង្គំលា។ តថាគតពោលតបថា បពិត្រមហារាជ សូមព្រះអង្គទ្រង់កំណត់កាលគួរ ក្នុងកាលឥឡូវនេះ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង ស្តេចជាធំទាំង៤ ក្រោកចាកអាសនៈ ហើយថ្វាយបង្គំតថាគត ធ្វើប្រទក្សិណ ហើយក៏បាត់ទៅក្នុងទីនោះឯង។ ម្នាលភិក្ខុទាំងឡាយ យក្ខទាំងអម្បាលនោះឯង លុះក្រោកចាកអាសនៈហើយ ពួកខ្លះថ្វាយបង្គំតថាគត ធ្វើប្រទក្សិណ ហើយក៏បាត់ទៅ ក្នុងទីនោះ ពួកខ្លះគ្រាន់តែពោលពាក្យរាក់ទាក់ សំណេះសំណាលជាមួយនឹងតថាគត លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹក ហើយក៏បាត់ទៅក្នុងទីនោះ ពួកខ្លះ គ្រាន់តែប្រណម្យអញ្ជលីចំពោះតថាគតហើយ ក៏បាត់ទៅក្នុងទីនោះ ពួកខ្លះ គ្រាន់តែប្រកាសនាម និងគោត្រហើយក៏បាត់ទៅ ក្នុងទីនោះ ពួកខ្លះគ្រាន់តែស្ងៀមៗ ហើយក៏បាត់ទៅក្នុងទីនោះ ។ម្នាល

ភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូររៀនព្រះបរិត្តសម្រាប់រក្សាក្នុងអាដានាដានគាថា ម្នាល ភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរទន្ទេញ ឲ្យចាំស្ទាត់ នូវព្រះបរិត្តសម្រាប់រក្សា ក្នុង អាដានាដានគាថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចាំទុកនូវព្រះបរិត្ត សម្រាប់រក្សា ក្នុងអាដានាដានគាថា ម្នាលភិក្ខុទាំងឡាយ ការរក្សាក្នុងអាដានាដានគាថានេះ ប្រកបដោយ ប្រយោជន៍ ប្រព្រឹត្តទៅ ដើម្បីគ្រប់គ្រងរក្សា ដើម្បីមិនបៀតបៀន ដើម្បីនៅជាសុខ ដល់ ពួកភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកា។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើ យ។ ភិក្ខុទាំងនោះ មានចិត្តត្រេកអរ ទទួលអនុមោទនានឹងភាសិត របស់ព្រះមានព្រះភាគ ដោយប្រការដូច្នេះ។

(ចប់ អាដានាដិយសូត្រ ទី៩ ក្នុងបិដក)

# អដ្ឋកថា អាដានាដិយសូត្រ ទី ៩

[៧៨] **ឯវំមេ សុតន្តិ អាដានាដិយសុត្តំ** តទៅនេះ ជាការពណ៌នាបទតាមលំដាប់ក្នុងសូត្រនោះ ។ បទថា **ត្រូវការរក្សាក្នុងទិសទាំងបួន** សេចក្តីថា តាំងរក្សាដល់ស្តេចសក្កៈដែលជាស្តេចទេវតាទាំងឡាយ ក្នុងទិសទាំង ៤ ដើម្បីការពារទ័ពអសុរ ។ បទថា **តាំងកងទ័ព** គឺ តាំងកងកម្លាំង ។ បទថា **តាំងអ្នកត្រួតត្រា** គឺ តាំងបន្ទាយរក្សាការពារក្នុងទិសទាំង ៤ ។ អធិប្បាយថា ស្តេចមហារាជទាំង ៤ បានចាត់ចែងរក្សាយ៉ាងល្អដល់ស្តេចសក្កៈទេវរាជ យ៉ាងនេះ ប្រថាប់អង្គុយក្នុងអាដានា-ដានគរ ប្រារព្ធដល់ព្រះពុទ្ធទាំងឡាយ ៧ ព្រះអង្គ ហើយចងគ្រឿងការពារនេះ ហើយប្រកាសថា នរណាមិនស្តាប់ធម្មអាជ្ញារបស់ព្រះសាស្តា និងរាជអាជ្ញារបស់យើង យើងនឹងធ្វើវត្ថុនេះ វត្ថុនេះ ដល់អ្នកនោះ ដូច្នេះ ហើយចាត់ចែងរក្សាដោយសេនា ៤ ពួក មានយក្ខសេនាធំជាដើម ក្នុងទិសទាំង ៤ របស់ខ្លួន កាលរាត្រីកន្លងទៅហើយ ។ល។ អង្គុយក្នុងកន្លែងដ៏សមគួរមួយ ។

**អតិក្កន្ត** សព្ទ ក្នុងបទនេះថា **កាលរាត្រីកន្លងទៅហើយ** ដូច្នេះ រមែងប្រាកដក្នុងសេចក្តីថា អស់ទៅដោយល្អ ល្អក្រៃលែង ត្រេកអរក្រៃលែងជាដើម ។ **អតិក្កន្ត** សព្ទ ក្នុងបទនោះ ប្រាកដក្នុង **ការអស់ទៅ** ក្នុងបទមានអាទិ៍យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន រាត្រីអស់ហើយ បឋមយាមកន្លងទៅហើយ ភិក្ខុសង្ឃអង្គុយចាំយូរហើយ សូមព្រះមាន-ព្រះភាគ ទ្រង់សម្តែងព្រះបាតិមោក្ខដល់ភិក្ខុទាំងឡាយចុះ ព្រះអង្គ ។ ក្នុងសេចក្តីថា ល្អ ក្នុងបទមានអាទិ៍យ៉ាងនេះថា ព្រះមានព្រះភាគ ល្អជាងនិងប្រណីតជាងបុគ្គល ៤ ពួកនេះ ដូច្នេះ ។ ក្នុងសេចក្តីថា **ស្មើស្អាត** ក្នុងបទមានជាអាទិ៍ថា ៖

**នរណាហ្ន៎ រុងរឿងដោយឫទ្ធិ ដោយយស មានរស្មី**
**ស្អាតក្រៃលែង ញុំាងទិសទាំងពួងឲ្យភ្លឺ មកថ្វាយបង្គំព្រះ**
**បាទានៃតថាគត** ដូច្នេះ ។

ក្នុងសេចក្តីថា គួរត្រេកអរក្រៃលែង ក្នុងបទមានជាអាទិ៍យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន គួរត្រេកអរក្រៃលែង បពិត្រព្រះគោតមដ៏ចម្រើន គួរត្រេកអរក្រៃលែង ដូច្នេះ ។ ដោយហេតុនោះ លោកទើប

ពោលថា ក្រើកទន្ទឹងទៅ គឺ ក្រើកអស់ទៅ ដូច្នេះ ។ **អភិក្កន្ត** ស័ព្ទ ក្នុងបទនេះថា មានរស្មីល្អក្រៃលែង ប្រព្រឹត្តទៅក្នុងរូបល្អក្រៃលែង ។ តែ វណ្ណ ស័ព្ទ រមែងប្រាកដក្នុងសេចក្តីថា សម្បុរ សរសើរ ត្រកូល ហេតុ សណ្ឋាន ប្រមាណ រូបាយតនៈ ជាដើម ។ ក្នុងបទទាំងឡាយនោះ វណ្ណ ស័ព្ទ ប្រព្រឹត្តទៅក្នុងសេចក្តីថា **សម្បុរ** ក្នុងបទ មានជាអាទិ៍យ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ព្រះអង្គ មានសម្បុរដូចមាស ។ វណ្ណ ស័ព្ទ ប្រព្រឹត្តទៅក្នុងសេចក្តីថា **សរសើរ** ក្នុងបទមានជាអាទិ៍យ៉ាងនេះថា ម្នាល គហបតី ក៏ការសរសើរព្រះសមណគោតម របស់លោក នឹងប្រាកដបាន ដូចម្តេច ដូច្នេះ ។ ប្រព្រឹត្តទៅក្នុងសេចក្តីថា **ជាតិត្រកូល** ក្នុងបទមាន ជាអាទិ៍យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ជាតិត្រកូល ៤ ទាំងនេះ ដូច្នេះ ។ ប្រព្រឹត្តទៅក្នុងសេចក្តីថា **ហេតុ** ក្នុងបទមានជាអាទិ៍យ៉ាងនេះថា អើ! ក៏ព្រោះហេតុអ្វីហ្ន៎ លោកទើបពោលថា ជាអ្នកលួចក្លិន ។ ប្រព្រឹត្ត ទៅក្នុងសេចក្តីថា **សណ្ឋាន** ក្នុងបទមានជាអាទិ៍យ៉ាងនេះថា និម្មិតទ្រង់ទ្រាយ ដូចជាស្តេចដំរីធំ ។ ប្រព្រឹត្តទៅក្នុងសេចក្តីថា **ប្រមាណ** ក្នុងបទមានជា អាទិ៍យ៉ាងនេះថា ខ្នាតនៃបាត្រមាន ៣ យ៉ាង ។ ប្រព្រឹត្តទៅក្នុងសេចក្តីថា

**រូបាយតនៈ** ក្នុងបទមានជាអាទិ៍យ៉ាងនេះថា រូប ក្លិន រស និង: ដូច្នេះ ។

វណ្ណ ស័ព្ទនោះ ក្នុងទីនេះគប្បីជ្រាបថា ប្រព្រឹត្តទៅក្នុងសេចក្តីថា **សម្បុរ** ។ ដោយហេតុនេះ លោកទើបពោលថា បទថា **មានស្មើស្អាតក្រៃលែង** គឺ មានសម្បុរស្អាតក្រៃលែង ដូច្នេះ ។

កេវល ស័ព្ទ ក្នុងបទថា កេវលកប្ប នេះ មានសេចក្តីមិនតិចជាដើមថា មិនមានចំណែកសល់ ដោយច្រើនមិនមានលាយឡំ មិនក្រៃលែងជាង តម្កល់មាំ បែកគ្នា ។ មានអធិប្បាយដោយប្រការនោះ គឺ កេវល ស័ព្ទ សេចក្តីថា **មិនមានចំណែកនៅសល់** ក្នុងបទមានជាអាទិ៍យ៉ាងនេះថា ព្រហ្មចរិយធម៌ដ៏បរិសុទ្ធ បរិបូណ៌ដោយអស់ជើង ។ មានសេចក្តីថា **ដោយច្រើន** ក្នុងបទមានជាអាទិ៍យ៉ាងនេះថា ជនអ្នកដែនអង្គៈ និងជនអ្នកដែនមគធៈ ទាំងអស់គ្នាប្រាថ្នានឹងកាន់យករបស់ទំពា របស់បរិភោគ ល្មមប្រមាណហើយ ក៏ចៀសចេញទៅ ដូច្នេះ ។ មានសេចក្តីថា **មិនលាយឡំ** ក្នុងបទមានជាអាទិ៍យ៉ាងនេះថា ជាហេតុកើតឡើងនៃកងទុក្ខសុទ្ធៗ ។ មានសេចក្តីថា **មិនក្រៃលែងជាង** ក្នុងបទមានជាអាទិ៍យ៉ាងនេះថា លោកដ៏មានអាយុនេះ ត្រឹមតែមានសទ្ធាមិនក្រៃលែងជាង ។ មានសេចក្តីថា

**តម្កល់មាំ** ក្នុងបទមានជាអាទិ៍យ៉ាងនេះថា ព្រះពាហិកៈ សទ្ធិវិហារិករបស់ព្រះអនុរុទ្ធ តាំងនៅក្នុងសន្ស្យកេទ យ៉ាងមុតមាំ ។ មានសេចក្ដីថា **បែកគ្នា** ក្នុងបទមានអាទិ៍យ៉ាងនេះថា ឧត្តមបុរសបែកគ្នាហើយ ដូច្នេះ ។ តែក្នុងទីនេះ កេវល ស័ព្ទ លោកបំណងយកសេចក្ដី គឺ មិនមានចំណែកសល់ ។

មួយវិញទៀត **កប្ប** ស័ព្ទនេះ មានសេចក្ដីច្រើនយ៉ាង ជាដើមថា ការជឿយ៉ាងក្រៃលែង វោហារ កាល បញ្ញត្តិ ការកាត់ វិកប្ប លេស សេចក្ដីដោយជុំវិញ ។ មានអធិប្បាយដោយប្រការនោះ គឺ **កប្ប** ស័ព្ទ មានសេចក្ដីថា **ការជឿយ៉ាងក្រៃលែង** ក្នុងបទមានជាអាទិ៍យ៉ាងនេះថា ក៏ព្រោះព្រះគោតមដ៏ចម្រើន ជាព្រះអរហន្តសម្មាសម្ពុទ្ធ គួរទុកចិត្តបាន ។ មានសេចក្ដីថា **វោហារ** ក្នុងបទមានជាអាទិ៍យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់ផ្លែឈើ ដោយវោហាររបស់សមណៈ ៥ យ៉ាង ។ មានសេចក្ដីថា **កាល** ក្នុងបទមានជាអាទិ៍យ៉ាងនេះថា បានឮថា ព្រះតថាគត នៅអស់កាលជានិច្ច ។ មានសេចក្ដីថា **បញ្ញត្តិ** ក្នុងបទមានជាអាទិ៍ យ៉ាងនេះថា លោកដ៏មានអាយុ ជាអ្នកបញ្ញត្តិទុកដោយប្រការដូច្នេះ ។ មានសេចក្ដីថា **កាត់** ក្នុងបទមានជាអាទិ៍យ៉ាងនេះ

ថា តាក់តែងហើយ គឺ កាត់សក់ និងកោរពុកមាត់ ។ មានសេចក្តីថា **វិកប្ប** ក្នុងបទមានជាអាទិ៍យ៉ាងនេះថា ប្រមាណពីរធ្នាប់ ទើបគួរ ។ មានសេចក្តីថា **លេស** ក្នុងបទមានជាអាទិ៍យ៉ាងនេះថា កេលេសដើម្បីទ័ងដេក ។ មានសេចក្តីថា **ដោយជុំវិញ** ក្នុងបទមានជាអាទិ៍យ៉ាងនេះថា ញុំាងវត្តវេឡុវ័នឲ្យស្វាងស្វៃដោយជុំវិញ ។ ក៏ក្នុងទីនេះ លោកបំណង **កប្ប** សព្ទ មានសេចក្តីថា **ដោយជុំវិញ** ។ ព្រោះដូច្នោះ ក្នុងបទនេះថា ញុំាងភ្នំគិជ្ឈកូដទាំងអស់ឲ្យភ្លឺស្វាង ដូច្នេះ គប្បីឃើញសេចក្តីយ៉ាងនេះថា ញុំាងភ្នំគិជ្ឈកូដឲ្យភ្លឺស្វាងដោយជុំវិញ មិនមានចំណែកសល់ ។

បទថា **ឲ្យភ្លឺស្វាង** សេចក្តីថា ផ្សាយព្រះរស្មីចេញចាកសរីរៈប្រដាប់ដោយសំពត់ និងផ្កាឈើ ។ អធិប្បាយថា ធ្វើឲ្យមានពន្លឺតែមួយ ឲ្យរុងរឿងតែម្យ៉ាង ដូចព្រះចន្ទ និងព្រះអាទិត្យ ។ បទថា **ឯកមន្តំ និសីទឹសុ** សេចក្តីថា ឈ្មោះថា ទីអន្ត្រយក្នុងសម្នាក់ព្រះទសពលនៃទេវតាទាំងឡាយមិនច្រើន ។ តែក្នុងព្រះសូត្រនេះ ពួកទេវតាអន្ត្រយដោយសេចក្តីគោរពព្រះបរិត្ត ។

# រឿងមហារាជទាំង ៤

[៧៩] បទថា **ស្តេចវេស្សវ័ណ** សេចក្តីថា ស្តេចមហារាជទាំង ៤ ស្តេចមកក៏ពិតមែន តែស្តេចវេស្សវ័ណ ជាអ្នកជិតជិតនឹងព្រះទសពល ឆ្លាតក្នុងការក្រាបទូល មានការសិក្សាយ៉ាងល្អ ព្រោះដូច្នោះ ស្តេចវេស្សវ័ណមហារាជ ទើបបានក្រាបទូលចំពោះព្រះមានព្រះភាគ ។ បទថា **អ្នកធំ** គឺ ជាអ្នកមានសក្តិធំ ដល់ព្រមដោយអានុភាព ។ បទថា **ដើម្បីវៀរចាកបាណាតិបាត** សេចក្តីថា ព្រះមានព្រះភាគទ្រង់សម្តែងទោស ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងភពខាងមុខ ក្នុងបាណាតិបាត ហើយទ្រង់សម្តែងធម៌ ដើម្បីឲ្យវៀរចាកបាណាតិបាតនោះ ។ សូម្បីក្នុងបទដ៏សេស ក៏ន័យនេះឯង ។ បទថា **យក្សអ្នកធំពួកខ្លះ ស្នាក់នៅក្នុងព្រៃនោះក៏មាន** សេចក្តីថា ក្នុងសេនាសនៈទាំងនោះ មានយក្សអ្នកធំស្នាក់នៅជាប្រចាំ ។ បទថា **អាដានាដិយ** សេចក្តីថា ឈ្មោះយ៉ាងនេះ ព្រោះចងឡើងក្នុងអាដានាដនគរ ។ សួរថា ឈ្មោះថា ធម៌ដែលមិនជាក់ច្បាស់ មានហើយក្នុងព្រះមានព្រះភាគឬ ។ ឆ្លើយថា មិនមាន ។ សួរថា កាលបើដូច្នោះ ព្រោះហេតុអ្វី ស្តេចវេស្សវ័ណ ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូម

ព្រះមានព្រះភាគមេត្តាប្រោសរៀនអាដានាដិយៈ រក្សាចុះព្រះអង្គ ដូច្នេះ ។ ឆ្លើយថា ដើម្បីរកឱកាស ។ ព្រោះថា ស្តេចវេស្សវ័ណនោះ ធ្លាប់បានឱកាសដើម្បីនឹងបានស្តាប់ព្រះបរិត្តនេះ អំពីព្រះមានព្រះភាគ ទើបក្រាបទូលយ៉ាងនេះ ។ បុរាណកបណ្ឌិតពោលថា កាលស្តេចវេស្សវ័ណ ក្រាបទូលចំពោះព្រះមានព្រះភាគ ហើយព្រះបរិត្តនេះនឹងជាគ្រូ ដូច្នេះខ្លះ ។ បទថា **ដើម្បីការពារនៅជាសុខ** សេចក្តីថា ដើម្បីនៅជាសុខក្នុងឥរិយាបថទាំង ៤ មានដើរ ឈរ ជាដើម ។

## គាថានមស្ការចំពោះព្រះសម្មាសម្ពុទ្ធ ៧ ព្រះអង្គ

[៨០] បទថា **មានចក្ខុ** សេចក្តីថា មិនមែនព្រះវិបស្សីសម្ពុទ្ធប៉ុណ្ណោះ មានចក្ខុ សូម្បីព្រះពុទ្ធ ៧ ព្រះអង្គ ក៏មានចក្ខុ ព្រោះដូច្នោះ ព្រះពុទ្ធមួយព្រះអង្គៗ រមែងមានឈ្មោះ ៧ យ៉ាងទាំងនេះ ។ សូម្បីព្រះពុទ្ធទាំងឡាយក៏មានចក្ខុ ទ្រង់អនុគ្រោះសត្វទូទៅ ទ្រង់ជម្រះកិលេស ព្រោះមានកិលេសដែលទ្រង់ជម្រះហើយ ទ្រង់ញាំញីមារ និងសេនាមារ ទ្រង់នៅចប់ព្រហ្មចរិយៈ ទ្រង់ផុតវិសេសហើយ មានព្រះនាមថា **អង្គីរស** ព្រោះរស្មី

ចេញចាកព្រះវរកាយ ។ មួយទៀត ឈ្មោះទាំង ៧ នេះ មិនមែនរបស់ព្រះពុទ្ធទាំងឡាយ ដោយអស់ដើង ។ លោកពោលថា លោកអ្នកស្វែងរកគុណធំ ដោយមានគុណ រមែងមានឈ្មោះ រាប់មិនបាន ។ ក៏ស្តេចវេស្សវ័ណពោលយ៉ាងនេះ ដោយអំណាចព្រះនាមដែលប្រាកដដល់ខ្លួន ។

ក្នុងបទថា **ជនទាំងនោះ** នេះ លោកបំណាងដល់បុគ្គលជាទីណា-ស្រព ។ បទថា **មិនសឹកសៀត** នេះ ត្រឹមតែជាកំពូលរបស់ទេសនា ។ អធិប្បាយថា មិននិយាយកុហក មិននិយាយសឹកសៀត មិននិយាយគ្រោតគ្រាត និយាយល្មមប្រមាណ ។ បទថា **មហន្តា** សេចក្តីថា ដល់ភាពជាបុគ្គលធំក្រៃលែង ។ បាលីថា **មហន្តា** ដូច្នេះ ។ សេចក្តីថា ធំ ។ បទថា **ប្រាសចាកការភ័យខ្លាច** គឺ មិនមានសេចក្តីខ្លាចអើល ប្រាសចាកការព្រឺរោម ដោយការខ្លាច ។ បទថា **ប្រយោជន៍ធំទូលាយ** គឺ ជាប្រយោជន៍ដោយការផ្សាយមេត្តា ។ ពាក្យថា **យំ** ក្នុងបទនេះថា **យំ ឆមស្សន្តិ** ត្រឹមតែនិបាត ។ បទថា **មហន្តំ** បានដល់ ធំ ។ មួយទៀត បាលីក៏យ៉ាងនេះ គឺ ជាការដែលលោកពោលបទនេះទុកថា បទថា ព្រះពុទ្ធជាម្ចាស់ពួកណា ដែលរលត់ហើយក្នុងលោក សេចក្តីថា ព្រះពុទ្ធទាំង

ឡាយ រលត់ហើយដោយការរលត់កិលេស ទ្រង់ឃើញច្បាស់តាមសេចក្តីពិត ។ ម្យ៉ាងទៀត ទេវតា និងមនុស្សទាំងឡាយ នមស្ការព្រះគោតមព្រះអង្គជាប្រយោជន៍ដល់ទេវតា និងមនុស្សទាំងឡាយ ទ្រង់បរិបូណ៌ដោយគុណធម៌ មានវិជ្ជាជាដើម ព្រះពុទ្ធទាំងឡាយសូម្បីទាំងនោះ មិនត្រាស់សឹកសៀត សូមកិរិយានមស្ការ ចូរមានចំពោះព្រះពុទ្ធសូម្បីទាំងនោះ ។ តែក្នុងអដ្ឋកថា ពោលថា បទថា **ជនទាំងឡាយនោះ ជាអ្នកមិនសឹកសៀត** សេចក្តីថា ព្រះពុទ្ធជាម្ចាស់ទាំងឡាយនោះ ជាអ្នកមិនសឹកសៀត ដូច្នេះ ។ ស្តេចវេស្សវ័ណមហារាជ ពោលសរសើរព្រះពុទ្ធទាំងឡាយ ដោយគាថាបទដំបូងយ៉ាងនេះ ព្រោះដូច្នោះ ស្តេចវេស្សវ័ណមហារាជ ពោលគាថាបទដំបូង ដោយអំណាចនៃព្រះពុទ្ធទាំងឡាយ ៧ ព្រះអង្គ ។ បទថា **ព្រះគោតម** ក្នុងគាថាទីពីរនេះ ត្រឹមតែជាទានមុខរបស់ទេសនា ។ គប្បីជ្រាបគាថាទីពីរនេះថា ស្តេចវេស្សវ័ណមហារាជ ពោលដោយអំណាចរបស់ព្រះពុទ្ធជាម្ចាស់ទាំង ៧ ព្រះអង្គ ដូចគ្នា ។ ក៏ក្នុងបទនេះ មានអធិប្បាយដូច្នេះថា ទេវតា និងមនុស្សទាំងឡាយ ដែលជាបណ្ឌិតក្នុងលោក រមែងនមស្ការព្រះគោតមព្រះអង្គណា សូមការនមស្ការ ចូរមានដល់ព្រះគោតមនោះ និង

ព្រះពុទ្ធទាំងឡាយ ដែលមានមកអំពីមុនព្រះគោតមនោះ ។

## វិរុឡ្ហកទេវរាជគង់ក្នុងទិសខាងត្បូង

[៨១] បទថា យតោ ឧគ្គច្ឆតិ សេចក្ដីថា រះឡើងអំពីកន្លែងណា ។ បទថា **ព្រះអាទិច្ច** បានដល់ បុត្ររបស់ព្រះអាទិត្យ ។ ឬថា បទនេះត្រឹមតែវេវចនៈរបស់ **សុរិយៈ** ស័ព្ទ ។ ព្រះអាទិត្យ ឈ្មោះថា មណ្ឌលធំ ព្រោះមានមណ្ឌលធំ ។ បទថា យស្ស ឧគ្គច្ឆមានស្ស សេចក្ដីថា គ្រាព្រះអាទិត្យណារះឡើងហើយ ។ បទថា សំវរីបិ និរុជ្ឈតិ សេចក្ដីថា ពេល យប់រមែងបាត់ទៅ ។ បទថា យស្ស ឧគ្គតេ សេចក្ដីថា គ្រាព្រះអាទិត្យរះឡើងហើយ ។ បទថា រហទោ សេចក្ដីថា អន្លង់ទឹក ។ បទថា **ក្នុងទីនោះ** សេចក្ដីថា ក្នុងទីដែលព្រះអាទិត្យរះឡើង ។ បទថា **សមុទ្ទោ** គឺ សមុទ្រណា លោកពោលថា អន្លង់ទឹក សមុទ្រនោះមិនមែនដទៃ គឺ សមុទ្រនោះឯង ។ បទថា **មានទឹកពេញប្រៀប** គឺ ទឹកហូរជន់ សេចក្ដីថា ទន្លេទាំងឡាយមានប្រការផ្សេងៗ ហូរទៅ ឬហូរចូលទៅក្នុងសមុទ្រនោះ ព្រោះហេតុនោះ ទើបឈ្មោះថា សមុទ្រមានទឹកពេញប្រៀប ។

បទថា **ជនទាំងឡាយមិនមែនដឹងអន្លង់ទឹកនោះ ក្នុងទីនោះយ៉ាងនេះ** ។ សេចក្ដីថា មិនមែនដឹងអន្លង់ទឹកនោះ ក្នុងទីនោះយ៉ាងនេះ ។ សួរថា តើដឹងបាន យ៉ាងណា ។ ឆ្លើយថា ដឹងបានយ៉ាងនេះថា សមុទ្រមានទឹកពេញប្រៀប ដូច្នេះ ។ បទថា **តាំងនេះទៅ** សេចក្ដីថា ពីក្នុងសិនេរុ ឬពីកន្លែងដែលពួក ទេវតាទាំងនោះអង្គុយ ។ បទថា **ជនោ** គឺ មហាជននេះ ។ បទថា **មានឈ្មោះតែមួយ** គឺ មានឈ្មោះតែមួយថា **ឥន្ទ** ។ បានឮថា ស្ដេច មហារាជទាំង ៤ បានតាំងឈ្មោះរបស់ស្ដេចសក្កទេវរាជ ឲ្យជាឈ្មោះ របស់ទិសទាំងនោះគ្រប់ព្រះអង្គ ។ បទថា **អសីតិ ទស ឯកោ ច** គឺ បុត្រ ៩១ ព្រះអង្គ ។ បទថា **ឥន្ទនាម** គឺ មានឈ្មោះយ៉ាងនេះថា **ឥន្ទៈ ឥន្ទៈ** ។ បទថា **ព្រះពុទ្ធជាម្ចាស់ទ្រង់ភ្ញាក់ហើយ ទ្រង់ជាផៅពង្សព្រះអាទិត្យ** សេចក្ដីថា ទ្រង់ភ្ញាក់ហើយ ព្រោះប្រាសចាកសេចក្ដីលក់ គឺ កិលេស ទ្រង់ជា ផៅពង្សព្រះអាទិត្យ ព្រោះទ្រង់មានគោត្រស្មើនឹងព្រះអាទិត្យ ។ បទថា **ព្រះអង្គទ្រង់ពិចារណាមើលមហាជនដោយសេចក្ដីឆ្លាត** សេចក្ដីថា ទ្រង់ ពិចារណាមើលមហាជនដោយព្រះសព្វញ្ញុតញ្ញាណ ដែលមិនមានទោស ឬ ដោយល្អិតល្អន់ ។ បទថា **សូម្បីអមនុស្សទាំងឡាយ ក៏នាំគ្នាថ្វាយបង្គំព្រះ**

**អង្គ** សេចក្តីថា សូម្បីអមនុស្សទាំងឡាយពោលថា ព្រះសម្ពុទ្ធទ្រង់ពិចារណាមើលមហាជនដោយសព្វញ្ញុតញ្ញាណហើយ ក៏នាំគ្នាថ្វាយបង្គំព្រះពុទ្ធ ព្រះអង្គនោះ ។ បទថា **សុតំ ឆេតំ អភិណ្ហសោ** សេចក្តីថា សេចក្តីប្រការនោះខ្ញុំព្រះអង្គទាំងឡាយបានស្តាប់រឿយៗ ។ បទថា **ខ្ញុំម្ចាស់ទាំងឡាយ សូមថ្វាយបង្គំព្រះជិនគោតម** សេចក្តីថា ពួកខ្ញុំព្រះអង្គសួរគេថា ពួកលោកថ្វាយបង្គំព្រះជិនគោតមឬ គេនាំគ្នាឆ្លើយថា ថ្វាយបង្គំព្រះជិនគោតម ។

**[៨២]** បទថា **ស្លាប់ហើយ ជនទាំងឡាយនាំគ្នាពោលថា ចូរនាំចេញទៅតាមទិសណា** សេចក្តីថា ជនដែលស្លាប់ហើយ ឈ្មោះថា **ប្រេត** ជនទាំងឡាយនាំគ្នាពោលថា ចូរនាំអ្នកដែលស្លាប់ហើយទាំងនោះ ចេញទៅតាមទិសណា ។ បទថា **និយាយសើកសៀត ដូចស៊ីសាច់ខ្នង** សេចក្តីថា អ្នកពោលសើកសៀតទុះឯង ដូចជាស៊ីសាច់ខ្នង ទិងតិះដៀលកំបាំងមុខ ជនទាំងឡាយនាំគ្នាពោលថា ទិងនាំជនទាំងនេះ ចេញទៅតាមទិសណា ។ លោកពោលយ៉ាងនេះថា ជនទាំងឡាយនាំអ្នកទាំងនោះ សូម្បីទាំងអស់ចេញតាមផ្លូវទិសទក្សិណ ចូរដុត ឬចូរទម្លាយ ឬចូរសម្លាប់ ខាងទិសទក្សិណនៃព្រះនគរ ដូច្នេះ ។

បទថា **អំពីនេះទៅទិសដែលជនទាំងឡាយហៅថា ទិសទក្សិណនោះ** សេចក្តីថា ជនទាំងឡាយនាំគ្នាពោលថា ចូរនាំអ្នកដែលពោលសឹកសៀតជាដើម ដែលស្លាប់ទៅហើយ ចេញទៅតាមទិសខាងត្បូង អំពីនេះទៅទិសដែលជនទាំងឡាយហៅថា ទិសទក្សិណនោះ ។ បទថា **អំពីនេះទៅ** សេចក្តីថា ពីភ្នំសិនេរុ ឬពីកន្លែងដែលទេវតាទាំងនោះអង្គុយ ។ បទថា **ជាម្ចាស់ ជាអ្នកធំរបស់កុម្ភណ្ឌ** សេចក្តីថា បានប្រាប់ថា ទេវតាទាំងនោះ ជាអ្នកមានពោះធំ ។ មួយទៀត កូនអណ្ឌៈរបស់ទេវតាទាំងនោះ ធំដូចឆ្នាំង ព្រោះដូច្នោះ លោកទើបពោលថា **កុម្ភណ្ឌៈ** ។

[៨៣] បទថា **ព្រះអាទិត្យលិចក្នុងទីណា** សេចក្តីថា ព្រះអាទិត្យអស្តង្គតដោយទិសាភាគណា ដោយទិសាភាគនោះ ។

## និយាយអំពីឧត្តរកុរុទ្វីបជាដើម

[៨៤] បទថា មហាមេរុ គឺ ស្តេចភ្នំឈ្មោះ **សិនេរុ** ។ បទថា **គួរជាទីមើល** គឺ ល្អមើល ព្រោះសម្រេចដោយមាស ។ សេចក្តីថា ខាងទិសបច្ចិមនៃភ្នំសិនេរុ សម្រេចដោយប្រាក់ . ខាងទិសទក្សិណសម្រេច

ដោយកែវមណី , ទានទិសបច្ឆិមសម្រេចដោយកែវផលិក , ទានទិសឧត្តរ សម្រេចដោយមាស , ទានទិសឧត្តរនោះ ជាទិសដែលមើលក្រោយខ្លួន ព្រោះ ដូច្នោះ ភ្នំសិនេរុ ជាភ្នំដែលគួរមើល ដោយទិសាភាគណា នេះជាទ្វីមសារ ក្នុងភ្នំសិនេរុនេះ ។ បទថា **មនុស្សា អមមា ជាយន្តិ** សេចក្តីថា មនុស្ស ទាំងឡាយកើតក្នុងឧត្តរកុរុទ្វីបនោះ ។

បទថា **មិនប្រកាន់ថាជារបស់ខ្លួន** សេចក្តីថា វៀរចាកសេចក្តី ប្រកាន់ថាជារបស់យើង សូម្បីក្នុងសំពត់ អាភរណៈ ទឹកផឹក និងរបស់ បរិភោគជាដើម ។ បទថា **មិនហួងហែងគ្នា** គឺ មិនហួងហែងដោយ សេចក្តីហួងហែងក្នុងស្ត្រី ។ អធិប្បាយថា បានឮថា មនុស្សទាំងនោះមិន មានការហួងហែងថា នេះកិរិយារបស់យើង ។ តម្រេកដោយសេចក្តី ពេញចិត្តរមែងមិនកើតឡើង ព្រោះឃើញដូចមាតា ឬប្អូនស្រី ។ បទថា **មិននាំនង្គ័លចេញទៅភ្ជួរ** សេចក្តីថា សូម្បីនង្គ័ល ក៏មិនត្រូវនាំចេញទៅ កាន់ស្រែ ដោយបំណងថា យើងនឹងធ្វើការងារកសិកម្មក្នុងស្រែនោះ ។ បទថា **ស្រូវសាលីដែលជាផលិតផលក្នុងស្រែ មិនត្រូវការភ្ជួររាស់** សេចក្តី ថា ស្រូវសាលីកើតឡើងឯង ក្នុងព្រៃដែលជាផ្ទៃដីដែលមិនចាំបាច់ភ្ជួរ ។

បទថា **ជាគ្រាប់អន្ទ្រ** គឺ អន្ទ្រនោះឯង ជាផលកើតឡើងក្នុងផ្ទៃដីនោះ ។ បទថា **ចម្អិនក្នុងចង្ក្រានដែលគ្មានភ្លើង** គឺ ចាក់អន្ទ្រចូលទៅក្នុងឆ្នាំង ហើយចម្អិនដោយភ្លើងដែលប្រាសចាកផ្សែង និងផេះ ។ បានឮថា ក្នុងទីនោះ ឈ្មោះ **ជោតិកបាសាណ** ។ ទីនោះ ជនទាំងឡាយដាក់ថ្ម ៣ ដុំ ហើយលើកឆ្នាំងឡើងអំពីខាងលើ ភ្លើងតាំងឡើងពីថ្ម ហើយចម្អិនបាយនោះ ។ បទថា **បរិភោគបាយពីឆ្នាំងនោះឯង** សេចក្តីថា បរិភោគភោជននោះឯង ពីឆ្នាំងបាយនោះ ។ មិនមានសម្ល ឬធាតុយ៉ាងដទៃ ។ មួយទៀតរសរបស់បាយនោះ ជារសតម្រូវចិត្តរបស់អ្នកបរិភោគយ៉ាងល្អ ។ ជនទាំងនោះ រមែងឲ្យដល់អ្នកមកដល់ទីនោះ ។ គ្រប់គ្នាឈ្មោះថា **ចិត្តកំណាញ់** រមែងមិនមាន ។ សូម្បីព្រះពុទ្ធ និងព្រះបច្ចេកពុទ្ធជាដើមទ្រង់មានឫទ្ធិច្រើន ស្តេចក៏យាងទៅកាន់ទីនោះ ហើយទទួលបិណ្ឌបាត ។

បទថា **ធ្វើមេគោឲ្យមានក្រចកតែមួយ ( ដូចក្រចកសេះ )** សេចក្តីថា យក្ខទាំងឡាយអ្នកនៅបម្រើស្តេចវេស្សវ័ណ ចាប់មេគោដែលមានក្រចកតែមួយជាពាហនៈដូចសេះ ហើយជិះមេគោនោះ ជាប់តាមទៅកាន់ទិសតូចទិសធំ គឺ ត្រាច់តាមទៅក្នុងទិសនោះៗ ។ បទថា **ធ្វើបសុសត្វ**

**ឲ្យមានក្រចកតែមួយ** សេចក្ដីថា ធ្វើបសុសត្វជើង ៤ ដ៏សេស វៀរមេគោ ឲ្យមានក្រចកតែមួយជាពាហនៈ ហើយជាប់តាមទៅកាន់ទិសតូចទិសធំ ។ បទថា **ធ្វើស្ត្រីឲ្យជាពាហនៈ** សេចក្ដីថា ធ្វើមាតុគ្រាមមានគតិឲ្យជាពាហនៈ ហើយអង្គុយលើខ្លួនមាតុគ្រាមនោះ ត្រាច់ទៅ ។ ន័យថា ខ្លួនរបស់ស្ត្រីមានគតិនោះអត់ទ្រាំ កាលទ័នទិនចុះ ។ ស្ត្រីក្រៅពីនេះប្រើទឹមជាយាន ។ បទថា **ធ្វើបុរសឲ្យជាពាហនៈ** សេចក្ដីថា ចាប់បុរសមកទឹមជាយាន ។ ម្យ៉ាងទៀត កាលចាប់ មិនអាចចាប់អ្នកជាសម្មាទិដ្ឋិបាន ។ ដោយច្រើន ចាប់ពួកដែលរស់នៅជាយដែន និងមនុស្សព្រៃ ។ បានឮថា អ្នកជនបទណាមួយ ក្នុងជំពូកនោះ អង្គុយដេកលក់ជិតព្រះថេរៈមួយរូប ។ ព្រះថេរៈសួរថា ឧបាសកលោកដេកលក់ហើយឬ ។ គេឆ្លើយថា ករុណាលោកម្ចាស់ ថ្ងៃនេះខ្ញុំអស់កម្លាំង ព្រោះបម្រើស្ដេចវេស្សវ័ណរហូតយប់ លោកម្ចាស់ ។ បទថា **ធ្វើក្មេងស្រីឲ្យជាពាហនៈ** សេចក្ដីថា ចាប់ក្មេងស្រីធ្វើជាពាហនៈដើម្បីទឹមរថ ។ សូម្បីក្នុងការចាប់ក្មេងប្រុសធ្វើជាពាហនៈ ក៏មានន័យនេះឯង ។ បទថា **បណ្ដាស្ត្រីបម្រើរបស់ព្រះរាជានោះ** សេចក្ដីថា ស្ត្រីដែលជាអ្នកបម្រើរបស់ព្រះរាជានោះ ។ បទថា

**យានជំរី យានសេះ** សេចក្តីថា មិនមែនយានគោតែម្យ៉ាងប៉ុណ្ណោះ ជិះសូម្បីយានជំរី យានសេះជាដើម ត្រាច់ទៅ ។

បទថា **យានទិព្វ** សេចក្តីថា យានទិព្វច្រើនយ៉ាង សូម្បីដទៃក៏បានប្រាកដដល់មនុស្សទាំងនោះ ។ យានទាំងនេះ ជាយានចូលទៅដល់មនុស្សទាំងនោះមុន ។ ក៏មនុស្សទាំងនោះ ដេកលើទីដេកដ៏ប្រសើរ ទីប្រាសាទ និងអន្ទុយលើតាំង និងអង្រឹងជាដើម ត្រាច់ទៅ ។ ដោយហេតុនោះ លោកទើបពោលថា ប្រាសាទ និងអង្រឹង ដូច្នេះ ។ បទថា **ប្រាកដដល់ស្តេចមហារាជអ្នកប្រកបដោយយស** សេចក្តីថា យានទាំងនេះ រមែងកើតឡើងដល់ស្តេចមហារាជអ្នកមានយស អ្នកព្រមដោយអានុភាពយ៉ាងនេះ ។

បទថា **និងស្តេចមហារាជនោះ ទ្រង់បាននិម្មិតនគរទុកក្នុងអាកាស** សេចក្តីថា ព្រះរាជានោះ ទ្រង់បាននិម្មិតនគរ មានអាជានាជានគរជាដើម ទាំងនោះទុកក្នុងអាកាស គឺ នគរទាំងឡាយបានមានហើយ ។ ក៏នគរមួយរបស់ស្តេចមហារាជនោះ បានឈ្មោះ អាជានាជា , នគរមួយឈ្មោះ កុសិនាជា , នគរមួយឈ្មោះ បកុសិនាជា , នគរមួយឈ្មោះ នាជបរិយា ,

នគរមួយឈ្មោះ បរកុសិជនាជា ។ បទថា **ទិសឧត្តរ មានកបិវត្ថុនគរ** សេចក្តីថា ត្រង់ទិសឧត្តរ មាននគរដទៃឈ្មោះ កបិវត្ថុនគរ តាំងនៅក្នុងទិសឧត្តរនោះ ។ បទថា **នគរមួយទៀតឈ្មោះ ជនោយៈ** សេចក្តីថា ក្នុងភាគដទៃនៃទិសឧត្តរនោះ មាននគរដទៃឈ្មោះ ជនោយៈ ។ បទថា **នរនវតិយនគរ** សេចក្តីថា នគរមួយទៀតឈ្មោះ នរនវតិយៈ ។ នគរមួយទៀតឈ្មោះ អម្ពរអម្ពរវតិយៈ ។ បទថា **អាឡកមន្ទា** សេចក្តីថា មានរាជធានីដទៃទៀតឈ្មោះ អាឡកមន្ទា ។

បទថា **ព្រោះដូច្នោះ មហាជនទើបហៅស្តេចកុវេរមហារាជថា** ស្តេចវេស្សវ័ណ ដូច្នេះ មានរឿងដំណាលថា កាលព្រះពុទ្ធមិនទាន់ឧប្បត្តិ ស្តេចមហារាជនេះ ជាព្រាហ្មណ៍ឈ្មោះ **កុវេរ** បានសាងរោងគៀបអំពៅ ប្រកបគ្រឿងយន្ត ៧ គ្រឿង ។ កុវេរព្រាហ្មណ៍បានឲ្យផលដែលកើតឡើងពីទីរោងគ្រឿងយន្តមួយកន្លែង ដល់មហាជនដែលមក ហើយបានធ្វើបុណ្យ ។ ផលកម្រៃដែលច្រើនជាង បានតាំងឡើងក្នុងទីនោះ ក្រៅពីរោងដ៏សេស ។ កុវេរព្រាហ្មណ៍ ជ្រះថ្លាដោយបុណ្យនោះ ទើបកាន់យកផលដែលកើតឡើងសូម្បីពីរោងដ៏សេស ឲ្យទាន ហេតុដល់អស់ពីរម៉ឺនឆ្នាំ ។ គេធ្វើកាល

កិរិយា ទៅកើតជាទេវបុត្រឈ្មោះ **កុវេរ** ក្នុងសួគ៌ជាន់ចាតុម្មហារាជិកា ។ តមកបានគ្រងរាជសម្បត្តិក្នុងរាជធានីឈ្មោះ **វិសាណៈ** ។ តាំងពីនោះមក ទើបហៅថា **ស្តេចវេស្សវ័ណ** ។

បទថា **រមែងប្រាកដមានមុខនាទីមួយផ្នែក** សេចក្តីថា យក្ខអ្នករក្សាព្រំដែន ១២ នាក់ផ្សេងទៀត ចូលទៅពិចារណា ដាស់តឿនទូវប្រយោជន៍ទាំងឡាយ រមែងប្រាកដជាអ្នកមានមុខនាទីមួយផ្នែក ។ បានឮថា យក្ខអ្នករក្សាព្រំដែនទាំងនោះ យកដំណើរទៅប្រកាសដល់យក្ខអ្នករក្សាទ្វារ ១២ នាក់ ។ យក្ខអ្នករក្សាទ្វារទាំងឡាយ ប្រកាសដំណើរនោះ ដល់ស្តេចមហារាជ ។ ឥឡូវនេះ ស្តេចមហារាជ កាលទ្រង់សម្តែងឈ្មោះរបស់យក្ខអ្នករក្សាព្រំដែនទាំងនោះ ទើបពោលពាក្យមានជាអាទិ៍ថា **តតោលៈ** ដូច្នេះ ។ បានឮថា បណ្តាយក្ខទាំងនោះ យក្ខម្នាក់ឈ្មោះ **តតោលា** ម្នាក់ឈ្មោះ **តត្តលា** ម្នាក់ឈ្មោះ **តតោតលា** ម្នាក់ឈ្មោះ **ឱជសី** ម្នាក់ឈ្មោះ **តេជសី** ម្នាក់ឈ្មោះ **តតោជសី** ១ ។

បទថា **សុរោរាជា** សេចក្តីថា ម្នាក់ឈ្មោះ **សុរោ** ម្នាក់ឈ្មោះ

១ = ឱជសី , តេជសី , តតោជសី អដ្ឋកថា ។ ម៉ដក ឱជសី , តេជសី , តតោជសី ។

ភជា ម្នាក់ឈ្មោះ **សុភេភជា** ។ បទថា **អរិដ្ឋោ នេមិ** សេចក្តីថា ម្នាក់ឈ្មោះ **អរិដ្ឋៈ** ម្នាក់ឈ្មោះ **នេមិ** ម្នាក់ឈ្មោះ **អរិដ្ឋនេមិ** ។

បទថា **ក្នុងវិសាណាភជធានីនោះ មានអន្លង់ទឹកឈ្មោះ ធរណី** សេចក្តីថា ក៏ក្នុងវិសាណាភជធានីនោះ មានអន្លង់ទឹកមួយឈ្មោះ ធរណី ដោយឈ្មោះ ។ លោកពោលថា មានស្រះបោក្ខរណីធំទទឹង ៥០ យោជន៍ ។ បទថា **ជាដែនដែលកើតពពក** សេចក្តីថា ពពកទាំងឡាយទទួលទឹកពីស្រះបោក្ខរណី ហើយធ្លាក់ចុះមក ។ បទថា **កើតភ្លៀងធ្លាក់** សេចក្តីថា ភ្លៀងធ្លាក់ជន់លិច ។ បានឮថា កាលពពកតាំងឡើងទៅ ទឹកចាស់រមែងហូរចេញពីស្រះបោក្ខរណីនោះ ។ ពពកតាំងឡើងទៅខាងលើ ញាំងស្រះបោក្ខរណីនោះ ឲ្យពេញដោយទឹកថ្មី ។ ទឹកចាស់ ជាទឹកមានក្នុងខាងក្រោម រមែងហូរចេញទៅ ។ កាលស្រះបោក្ខរណីមានទឹកពេញ ពពករមែងរសាត់ទៅ ។ បទថា **សភា** គឺ ទីកន្លែងប្រជុំ ។ ត្រង់ជាំងស្រះបោក្ខរណីនោះ មានមណ្ឌបកែវប្រមាណ ១២ យោជន៍ ហោមព័ទ្ធដោយវល្លិ៍ឈ្មោះ **កត-លតា** ។ នេះលោកពោលសំដៅដល់មណ្ឌបនោះ ។ បទថា **មយិរុចាសង្គិ** សេចក្តីថា អន្ទ្រយហើយ ។ បទថា **ដើមឈើមានផ្លែច្រើន** សេចក្តីថា

មណ្ឌបកែវរមែងសម្ដែងដល់អត្ថថា ដើមឈើ មានស្វាយ និងព្រីងជាដើម ដុះលោមព័ទ្ធមណ្ឌបនោះ ក្នុងទីនោះ ផ្សាយទៅគ្រប់វេលា និងផ្កាឈើ មានផ្កាចម្បាជាដើម រីកស្គុះស្គាយជានិច្ច ។ បទថា **ប្រកបដោយពួកបក្សីច្រើនប្រភេទ** គឺ ដេរដាសដោយពួកបក្សីផ្សេងៗ ។ បទថា **មានសត្វក្ងោកសត្វក្រៀល មានសំឡេងពីរោះ** សេចក្ដីថា សត្វក្ងោក សត្វក្រៀល មានសំឡេងពីរោះ កងរំពង ។

បទថា **ក្នុងទីនោះមានសំឡេងបក្សីយំថា ជីវៈ ជីវៈ** សេចក្ដីថា ក្នុងទីនេះ មានសំឡេងសត្វឈ្មោះ **ជីវៈ ជីវកៈ** ស្រែកយ៉ាងនេះថា ជីវៈ ជីវៈ ដូច្នេះ ។ បទថា **មានសំឡេងគួរឲ្យរីករាយ** សេចក្ដីថា សូម្បីសត្វមានសំឡេងគួរឲ្យរីករាយ ក៏ស្រែកយ៉ាងនេះ ក្រោកឡើងចិត្តៈ ក្រោកឡើងចិត្តៈ ដូច្នេះ រមែងត្រាច់ទៅក្នុងទីនោះ ។ បទថា **មាន់** គឺ មាន់ព្រៃ ។ បទថា **ក្ដាម** គឺ ក្ដាមមាស ។ បទថា **ក្នុងព្រៃ** គឺ ក្នុងស្រះឈូក ។ បទថា ពោក្ខរសាតកា បានដល់ ពួកបក្សីឈ្មោះ **ពោក្ខរសាតកា** ។ បទថា សុកសាលិកសទ្ទេត្ថ សេចក្ដីថា ក្នុងស្រះនោះមានសំឡេងសត្វសេក និងសត្វសាលិកា ។ បទថា **ពួកបក្សីទណ្ឌមាណវក** គឺ សត្វមានមុខដូច

មនុស្ស ។ បានឮថា បក្សីទាំងនោះ យកជើងទាំងពីរចាប់ឈើមាស ហើយផាន់ស្លឹកឈូកណាមួយ ដាក់ឈើមាសលើឈូកមិនឲ្យចន្ទោះ ហើយត្រាច់ទៅ ។

បទថា **សតូភាសំ សរា** សេចក្តីថា ស្រះបោក្ខរណីនោះ ល្អសព្វៗ កាល ។ បទថា **ស្រះទិពិនីរបស់ស្តេចកុវេរ:** សេចក្តីថា ស្រះទិពិនីរបស់ស្តេចកុវេរ: ជាស្រះបទុម ស្រះនោះឈ្មោះ **ធរណី** ល្អសព្វៗ កាល ។

[៨៤] ស្តេចវេស្សវ័ណ ញុំាងអាជានាធិយាក្យា ឲ្យសម្រេចហើយ កាលនឹងសម្តែងការបរិកម្មព្រះបរិត្តនោះ ទើបពោលបទនេះថា **បុគ្គលណាមួយ** ។ ក្នុងបទទាំងនោះ បទថា **រៀនល្អហើយ** សេចក្តីថា អាជានា-ធិយាក្យា ដែលអ្នកណាម្នាក់ ជម្រះអត្ថ និងព្យញ្ជនៈ និងរៀនដោយល្អ ។ បទថា **រៀនជំនាញហើយ** សេចក្តីថា មិនឲ្យបទ និងព្យញ្ជនៈសាបសូន្យ ហើយរៀនដោយសព្វគ្រប់ ។ លោកសម្តែងទុកថា ពិតណាស់ ព្រះបរិត្ត រមែងមិនមានតេជៈដល់អ្នកពោលខុសអត្ថខ្លះ បាលីខ្លះ ឬថា មិនធ្វើឲ្យជំនាញ ។ ព្រះបរិត្ត រមែងមានតេជៈដល់អ្នកធ្វើឲ្យជំនាញ ដោយប្រការទាំងពួង ហើយពោលពិតប្រាកដ ។ សូម្បីកាលរៀន ព្រោះលាភជាហេតុ

ហើយពោល ក៏មិនសម្រេចប្រយោជន៍ ។ ព្រះបរិត្ត រមែងមានប្រយោជន៍ដល់អ្នកតាំងនៅក្នុងចំណែកនៃការចេញចាកទុក្ខ ហើយធ្វើមគ្គាឲ្យជាបុរេ-ចារិក ពោលហើយនុ៎ះឯង ។

បទថា **យក្ខុបចារ** គឺ អ្នកបម្រើយក្ខ ។ បទថា **វត្ថុំ** បានដល់ វត្ថុ គឺ ផ្ទះ ។

បទថា **ទីនៅ** បានដល់ ការនៅជានិច្ចក្នុងផ្ទះនោះ ។ បទថា **សមិតី** គឺ ការសមាគម ។

បទថា **អនុយ្យុំ** សេចក្ដីថា មិនគួរធ្វើការអាវាហៈ ។ បទថា **អវិវយ្យុំ** សេចក្ដីថា មិនគួរធ្វើការវិវាហៈជាមួយនឹងគេ ។ សេចក្ដីថា មិនគប្បីធ្វើការអាវាហៈ ឬវិវាហៈនឹងគេ ។

បទថា ដោយពាក្យជេរដែលបរិបូរ ដូចពោលហើយ សេចក្ដីថា អមនុស្សទាំងឡាយ គប្បីបង្អោនចូលទៅកាន់អត្តភាពរបស់យក្ខទាំងនោះ យ៉ាងនេះថា អ្នកមានភ្នែកពណ៌ក្រហម អ្នកមានធ្មេញលឿង ដូច្នេះ ហើយ បរិភាសដោយពាក្យបរិភាស ដែលមានព្យញ្ជនៈបរិបូណ៌ ដូចដែលពោលហើយ ។ អធិប្បាយថា ជាពាក្យជេររបស់យក្ខ ។ បទថា **បាត្រសូម្បីទទេ**

សេចក្តីថា បាត្រលោហៈ ដូចគ្នានឹងបាត្ររបស់ភិក្ខុនោះឯង ។ បាត្រនោះគ្របលើសីសៈរហូតដល់ក ។ យកសសរដែកដំបាត្រនោះត្រង់កណ្តាល ។ បទថា ចណ្ឌា គឺ ក្រោធ , រុទ្ធា បានដល់ កំហុស ។ បទថា រោសា គឺ ធ្វើហួសហេតុ ។

បទថា **មិនធ្វើស្តេចមហាភិជ** គឺ មិនកាន់យកពាក្យនិយាយ មិនធ្វើតាមការបង្គាប់ ។

បទថា **សេនាបតីរបស់មហាភិជ** គឺ សេនាបតីយក្ខ ២៨ នាក់ ។ បទថា **បុរិសកាដំ បុរិសកាដំ** គឺ អនុសាសន៍របស់សេនាបតីយក្ខ ។ បទថា **អវរុទ្ធានាម** សេចក្តីថា បច្ចាមិត្ត គឺ មានពៀរ ។ បទថា **ប្រកាសឲ្យដឹង** សេចក្តីថា អ្នកមិនអាចនឹងពោលព្រះបរិត្ត ឲ្យពួកអមនុស្សចៀសចេញបាន គួរប្រកាសឲ្យយក្ខទាំងឡាយដឹង សេចក្តីថា ឲ្យយក្ខទាំងនោះដឹង ។ ក៏ប៉ុន្តែថា គប្បីឈរក្នុងទីនេះ ហើយពោលបរិកម្មព្រះបរិត្ត ។ តាមពិត មិនគួរសូត្រអាដានាដិយសូត្រមុនទេ ។ គួរសូត្រព្រះសូត្រទាំងនេះ គឺ មេត្តសូត្រ ធជគ្គសូត្រ រតនសូត្រ រហូត ៧ ថ្ងៃ ។ ប្រសិនបើរួចផុតទៅបាន ជាការល្អ ។ ប្រសិនបើមិនរួចផុត គួរសូត្រអាដានាដិយ-

សូត្រ ។ ភិក្ខុដែលសូត្រអាដានាដិយសូត្រនោះ មិនគួរទំពារម្សៅ ឬសាច់ មិនគួរនៅក្នុងព្រៃស្មសាន ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ពួកអមនុស្សនឹងបានឱកាស ។ ទីដែលសូត្រព្រះបរិត្ត គួរធ្វើទីសូត្រឲ្យមានស្អោទៀស្រស់ ក្រាលអាសនៈឲ្យរៀបរយក្នុងទីនោះ ហើយគប្បីអង្គុយ ។ ភិក្ខុអ្នកសូត្រព្រះបរិត្ត ដែលជនទាំងឡាយនាំចេញពីវិហារទៅកាន់ផ្ទះ គួរលោមព័ទ្ធដោយគ្រឿងការពារ គឺ ក្តា ហើយគប្បីនាំទៅ ។ មិនគួរអង្គុយសូត្រក្នុងទីវាល ។ ភិក្ខុគួរបិទទ្វារ និងបង្អួចហើយ ទើបអង្គុយ លោមព័ទ្ធដោយដៃជាអាវុធ គឺ មេត្តាចិត្តក្នុងខាងដើម ហើយសូត្រ ។ គួរឲ្យទទួលសិក្ខាបទមុន ហើយសូត្រព្រះបរិត្តដល់អ្នកតាំងនៅក្នុងសីល ។ សូម្បីយ៉ាងនេះ ក៏មិនអាចនឹងរួចផុតបាន គួរនាំទៅកាន់វិហារ ឲ្យដេកលើលានព្រះចេតិយ ឲ្យធ្វើអាសនៈបូជា តាំងប្រទីប បោសសំអាតលានព្រះចេតិយ ហើយសូត្រមង្គលកថា ។ គួរប្រកាសឲ្យប្រជុំទាំងអស់ ។ ទីជិតវិហារ ដើមឈើធំ គួរបញ្ជូនដំណឹងទៅក្នុងទីនោះថា ពួកភិក្ខុរមែងរង់ចាំការមករបស់ពួកលោក ។

ឈ្មោះថា ការមិនមកក្នុងទីប្រជុំទាំងអស់ នឹងមិនបានទទួល គតិ

នោះ គួរសួរអ្នកដែលត្រូវអមនុស្សស្ថិតនៅថា លោកឈ្មោះអ្វី ។ កាលគេប្រាប់ឈ្មោះហើយ គួរហៅឈ្មោះតែម្តង ។ អ្នកគួរលែងបុគ្គលឈ្មោះនេះ ព្រោះចំណែកបុណ្យក្នុងការបូជាដោយវត្ថុ បានចងយកទុក និងរបស់ក្រអូបជាដើម ចំណែកបុណ្យក្នុងការបូជាអាសនៈ ចំណែកបុណ្យក្នុងការថ្វាយបិណ្ឌបាតរបស់គេ ពួកភិក្ខុសូត្រមហាមង្គលកថា ដើម្បីប្រយោជន៍ដល់បណ្ណាការរបស់គេ ដោយសេចក្តីគោរពក្នុងពួកភិក្ខុ សូមអ្នកចូរចេញពីគេចុះ ដូច្នេះ បើអមនុស្សមិនចេញ គួរប្រាប់ដល់ទេវតាទាំងឡាយថា ពួកលោកចូរដើងចុះ អមនុស្សនេះ មិនធ្វើតាមពាក្យរបស់ពួកយើង យើងនឹងធ្វើពុទ្ធអាជ្ញា ដូច្នេះ គួរសូត្រព្រះបរិត្តនេះ នេះជាបរិកម្មរបស់គ្រហស្ថ ។ ក៏បើភិក្ខុត្រូវអមនុស្សស្ថិត គួរលាងអាសនៈ ហើយប្រកាសឲ្យប្រជុំភិក្ខុទាំងអស់ ឲ្យចំណែកបុណ្យក្នុងការបូជា មានរបស់ក្រអូប និងផ្កាឈើជាដើម ហើយគប្បីសូត្រព្រះបរិត្តនេះ នេះជាបរិកម្មរបស់ភិក្ខុទាំងឡាយ ។ បទថា **គប្បីប្រជុំគ្នា** សេចក្តីថា គប្បីប្រកាសឲ្យសេនាបតីយក្ខ ២៨ នាក់ប្រជុំគ្នាទាំងអស់ ។ បទថា **គប្បីប្រាប់** សេចក្តីថា គប្បីប្រាប់ទេវតាទាំងឡាយនោះថា យក្ខនេះស្ថិតក្នុងគេ ដូច្នេះជាដើម ។ បទថា **ជាប់តាម**

ជាវេវចនៈរបស់បទថា **ស្កឹត** ម្យ៉ាងទៀត លោកពោលថា **ចូល** គឺ មិនចេញទៅ ។ បទថា **បៀតបៀន** សេចក្តីថា បៀតបៀនធ្វើឲ្យកើតរោគគម្រើករឿយៗ ។ បទថា **ធ្វើឲ្យកើតទុក្ខ** គឺ ធ្វើឲ្យមានសាច់ និងឈាមតិច ឲ្យកើតទុក្ខ ។ បទថា **មិនលែង** គឺ ជាអ្នកត្រូវក្រពើពាំ មិនប្រាថ្នានឹងលែង គប្បីប្រាប់ទៅតាមទាំងនោះ ដោយប្រការដូច្នេះ ។

## ពួកអមនុស្សមានយក្សជាដើម

[៨៦] ឥឡូវនេះ ដើម្បីសម្តែងដល់យក្សដែលគួរប្រាប់ ទើបពោលពាក្យជាដើមថា **នៃយក្សទាំងឡាយពួកណា** ដូច្នេះ ក្នុងបទទាំងនោះ បទជាដើមថា **ឥន្ទៈ សោមៈ** ជាឈ្មោះរបស់យក្សទាំងឡាយនោះ ។ បណ្តាយក្សទាំងឡាយនោះ យក្សមួយអាស្រ័យនៅលើភ្នំឈ្មោះវេសុភមិត្តៈ ឈ្មោះថា យក្សវេសុភមិត្តៈ ។ យក្សដែលអាស្រ័យនៅលើភ្នំយុគន្ធរៈ ឈ្មោះថា យក្សយុគន្ធរៈ គឺ យក្សឈ្មោះ ហិរិ នេត្តិ មណ្ឌិយៈ មណិ មណិវរៈ ទីឃៈ និងសេរីសកៈ និងយក្សទាំងនោះ ។

[៨៧] បទថា **គួរប្រកាសឲ្យយក្សតូច យក្សធំ ពួកសេនាបតី**

**ពួកមហាសេនាបតី** សេចក្តីថា គប្បីប្រាប់ដល់យក្ខសេនាបតីទាំងឡាយនេះយ៉ាងនេះថា យក្ខនេះបៀតបៀនអ្នកនេះ ធ្វើអ្នកនេះឲ្យក្តៅក្រហាយ មិនលែងអ្នកនេះ ដូច្នេះ បន្ទាប់ពីនោះ យក្ខសេនាបតីទាំងឡាយនោះ នឹងធ្វើសេចក្តីខ្វល់ខ្វាយថា ពួកភិក្ខុ រមែងធ្វើធម្មអាជ្ញារបស់ខ្លួន សូម្បីយើងនឹងធ្វើអាជ្ញារបស់ស្តេចយក្ខរបស់យើងទាំងឡាយ ។

[៨៨-៩១] ស្តេចវេស្សវណមហារាជកាលនឹងសម្តែងថា ទីការសរបស់ពួកអមនុស្សនឹងមិនមាន ដោយអាការយ៉ាងនេះ ពុទ្ធសាវកទាំងឡាយក៏នឹងនៅសប្បាយ ទើបក្រាបទូលមានពាក្យជាអាទិ៍ថា **បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ អដានាដិយរក្សា នេះឯង** ដូច្នេះ ។ បទទាំងអស់នោះ និងបទដទៃពីនោះ មានសេចក្តីងាយហើយនោះឯង ។

**( ចប់ អដ្ឋកថា អាដានាដិយសូត្រទី ៩ )**

# ការពណ៌នា អាដានាដិយសូត្រ ទី ៩ (ដីកាចារ្យ)

*ក្រើនបទថា* **ចតុទ្ទិសំ រក្ខំ ឋបេត្វា** *(តម្កល់ទុកនូវការរក្សាក្នុងទិសទាំងបួន) មានសេចក្តីថា តម្កល់ទុកនូវការរក្សានេះ ក្នុងឋាន : ២ និងទិសទាំង ៤ លោកពោលសំដៅដល់ការរក្សានេះ គឺលោកពោលបង្ហាញនូវបទទាំង ២ នោះ មានបទថា អសុរសេនា (សេនានៃអសុរ) ជាដើម ។ ក៏ក្នុងន័យនេះ បណ្តាការរក្សាទាំង ៤ នោះ គឺការរក្សាក្នុងឋាន : ៤ និងក្នុងទិសទាំង ៤ នេះ ដោយការរក្សាខ្លួនផង និង ដោយសេចក្តីមិនប្រមាទផង ។ ក៏សេចក្តីបដិសេធនៃអសុរសេនាឯណា ជាការរក្សានៃសក្កជាទេវានមិន្ទក្នុងទិសទាំង ៤ ក្នុងទេវបុរីជាសេចក្តីមិនប្រមាទក្នុងន័យ(អធិការ) របស់ខ្លួននោះ ។ម្យ៉ាងវិញទៀត ការរក្សាក្នុងទិសទាំងបួនក្នុងការចូលទៅកាន់សំណាក់នៃព្រះដ៏មានព្រះភាគនៃទេវតាទាំងនោះឯណា ជាការមិនប្រមាទដោយការរក្សាផ្ញើរបស់ខ្លួននោះ ។ព្រោះហេតុនោះ បានជាលោកពោលថា ដើម្បីកិរិយារាំងនៃពួកអសុរសេនា ជាដើម ។ កាលលោកពោលនូវអត្ថនោះដោយអំណាចនៃបញ្ចមីវិភត្តិក្នុងព្រះបាលីថា* **ចតុទ្ទិសំ** *(ក្នុងទិសទាំងបួន) ជាពាក្យចូលទៅសង្គ្រោះក្នុងបញ្ចមីវិភត្តិ ទើបលោកពោលថា* **ចតូសុ ទិសាសុ** *(ក្នុងទិសទាំង ៤) ។*

*ពីរបទថា* **អារក្ខំ ឋបេត្វា** *(តម្កល់ទុកនូវការរក្សា) មានសេចក្តីថា បពិត្រព្រះសម្មតិទេព មហារាជទាំង ៤ មាន ស្តេចវេស្សវ័ណ ជាដើម បានតម្កល់ទុក បានជ្រាបហើយនូវការគ្រប់គ្រងរក្សាក្នុងទិសទាំងឡាយ ដែលខ្លួនគប្បីរក្សាជារបស់ខ្លួនៗ ។*

*ពីរបទថា* **ពលគុម្ពំ ឋបេត្វា** *(ឋិតនៅហើយ ក្នុងគុម្ពឈើធំ) មានសេចក្តីថា ឋិតនៅហើយចំពោះពួកពលសេនា មានសេនាយក្សជាដើម។*

*ពីរបទថា* **ឱវរណំ ឋបេត្វា** *(ឋិតនៅហើយ ត្រង់គុម្ពឈើ) មានសេចក្តីថា បានឋិតនៅដើម្បីហាមឃាត់គូបដិបក្ខគ្នានិងគ្នា ។...........................................................................។*